អនុក្រឹត្យនេះ មានគោលបំណង ធានាសុខដុមនីយកម្មរវាងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ប្រកបដោយសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ដែលតទៅនេះហៅថា **យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល** និងសរសេរជាអក្សរកាត់ថា "**យ.ស.ក.**"។

**មាត្រា២._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការកែទម្រង់ទាំងអស់របស់រាជរដ្ឋាភិបាល ដែលមានទំនាក់ទំនងជាមួយនឹងកម្មវិធីកែទម្រង់ទាំង ៤ ខាងលើ។

## ជំពូកទី២

## មុខងារ និង ភារកិច្ច

**មាត្រា៣._**

**យ.ស.ក.** ជាយន្តការដឹកនាំនិងសម្របសម្រួលផ្លាស់វេនប្រចាំត្រីមាសរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

**មាត្រា៤._**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ជាប្រធានទទួលវេនដឹកនាំនិងសម្របសម្រួល **យ.ស.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សានិងកំណត់បញ្ហាប្រឈមនិងសំណើដំណោះស្រាយទាំងឡាយដែលមានចរិតអន្តរកែទម្រង់ ដើម្បីជាប្រធានបទពិភាក្សានិងសម្រេចក្នុងក្របខ័ណ្ឌ **យ.ស.ក.**
- ដឹកនាំនិងសម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗ ព្រមទាំងលើកសំណើសកម្មភាពឬសំណើដំណោះស្រាយជាគម្រោងការងារឬបេសកកម្មការងារដែលមានចរិតលក្ខណៈអន្តរកែទម្រង់ តាមសំណើរបស់លេខាធិការដ្ឋានកែទម្រង់ណាមួយ តាមបញ្ជារបស់ប្រធានគណៈកម្មាធិការកែទម្រង់ ឬតាមការចាំបាច់
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពសុខដុមនីយកម្មការកែទម្រង់ ៣ បូក ១
- រៀបចំនិងកំណត់របៀបវារៈប្រជុំ **យ.ស.ក.** ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬតាមការចាំបាច់
- រៀបចំនិងធានាដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់
- រៀបចំរបាយការណ៍កិច្ចប្រជុំជូនប្រធានគណៈកម្មាធិការកែទម្រង់ទទួលបន្ទុក ស្របតាមនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យនេះ
- រៀបចំ សម្របសម្រួល និងដឹកនាំការងារអន្តរកែទម្រង់ផ្សេងទៀតតាមការចាំបាច់។

**មាត្រា៥._**

អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ដែលជាប្រធានទទួលវេនត្រីមាសនីមួយៗ គឺជា "**ប្រធាន យ.ស.ក.**" ប្រចាំត្រីមាសនោះ។ អគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋានកែទម្រង់ អាចប្រគល់សិទ្ធិនេះជូនអគ្គលេខាធិការរង ឬ អនុប្រធានលេខាធិការដ្ឋានទទួលបន្ទុក ដឹកនាំជំនួសបាន។

ប្រធាន **យ.ស.ក.** ត្រូវធានាការអនុវត្តតាមតួនាទីនិងភារកិច្ចដូចមានកំណត់ក្នុងមាត្រា ៤ ប្រកបដោយភាពទៀងទាត់ ប្រក្រតីភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្នុងស្មារតីវិជ្ជាជីវៈនិយម ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ និងភាពជាអ្នកកែទម្រង់ខ្ពស់។

ប្រធាន **យ.ស.ក.** ត្រូវដឹកនាំកិច្ចប្រជុំប្រចាំត្រីមាស ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ។

ប្រធាន **យ.ស.ក.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងតំណាងអង្គភាពក្រោមឱវាទក្រសួងដឹកនាំការងារកែទម្រង់នីមួយៗ ឬ ដៃគូអភិវឌ្ឍន៍នានា ចូលរួមប្រជុំបានតាមការចាំបាច់។

**មាត្រា៦._**

ក្នុងករណីចាំបាច់ឬមានសំណើពីអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ណាមួយខាងលើ ការទទួលនិងដឹកនាំសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសអាចប្រព្រឹត្តទៅក្រោមទម្រង់ជាសហប្រធាន។

**មាត្រា៧._**

អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវម្ចាស់ការសម្របសម្រួលស្ថាប័ននិងអង្គភាព ដែលជាតួអង្គអនុវត្តពាក់ព័ន្ធក្រោមកម្មវិធីកែទម្រង់រៀងៗខ្លួន ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាព របាយការណ៍ និងការដោះស្រាយបញ្ហាប្រឈមនានា ដើម្បីធានាការចូលរួមអនុវត្ត **យ.ស.ក.** ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

## ជំពូកទី៣
## កិច្ចដំណើរការ

**មាត្រា៨._**

**យ.ស.ក.** ត្រូវមានផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

ផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវអនុម័តយ៉ាងយូរក្នុងសប្តាហ៍ទី៤នៃឆ្នាំបន្ទាប់។ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេនប្រចាំត្រីមាសទី៤ និងត្រីមាសទី១នៃឆ្នាំបន្ទាប់ ត្រូវសហការគ្នានិងទទួលខុសត្រូវរៀបចំ និងបូកសរុបផែនការសកម្មភាព ប្រចាំត្រីមាសនិងប្រចាំឆ្នាំ។

**មាត្រា៩._**

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ ត្រូវរៀបចំ បូកសរុប ត្រួតពិនិត្យតាមដាន និងត្រូវដាក់ជារបៀបវារៈពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំត្រីមាស។

អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានកែទម្រង់នីមួយៗ ត្រូវទទួលបន្ទុកសម្របសម្រួលនិងបូកសរុបរបាយ-ការណ៍វឌ្ឍនភាពដែលស្ថិតក្រោមការទទួលបន្ទុករបស់ខ្លួន និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានដែលជាប្រធានទទួលវេន យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែបន្ទាប់ ដើម្បីបូកសរុបសម្រាប់កិច្ចប្រជុំប្រចាំត្រីមាស។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការកែទម្រង់ទាំងបួន អាចចេញសេចក្តីសម្រេចរួមដើម្បីកំណត់វិធាននិងនីតិវិធីលម្អិតនៃការរៀបចំ ការអនុវត្ត និងការពិនិត្យតាមដាន និងវាយតម្លៃលើផែនការសកម្មភាព។

**មាត្រា១០.-**

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវរៀបចំឡើងយ៉ាងយូរបំផុតនៅក្នុងសប្តាហ៍ទី ៤ នៃត្រីមាសបន្ទាប់។

កិច្ចប្រជុំប្រចាំត្រីមាស ត្រូវសម្រេចលើរបៀបវារៈកំណត់ដោយប្រធានកិច្ចប្រជុំ និងត្រូវសម្រេចលើការកំណត់អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ ដែលត្រូវទទួលបន្ទុកជាប្រធាន **យ.ស.ភ.** នៃត្រីមាសបន្ទាប់។

របាយការណ៍កិច្ចប្រជុំ ត្រូវរៀបចំគោរពជូនប្រធានគណៈកម្មាធិការកែទម្រង់ដែលជាប្រធានទទួលវេន ដើម្បីពិនិត្យនិងសម្រេច មុននឹងចម្លងជូនអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀត ដើម្បីពិនិត្យនិងសហការអនុវត្ត។

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ប្រធាន **យ.ស.ភ.** អាចស្នើសុំរៀបចំកិច្ចប្រជុំវិសាមញ្ញ ដើម្បីពិភាក្សានិងលើកសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមជាក់លាក់ណាមួយ។

**មាត្រា១១.-**

ក្នុងករណីដែលអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានជាប្រធានទទួលវេន ខកខានឬយឺតយ៉ាវក្នុងការរៀបចំកិច្ចប្រជុំប្រចាំត្រីមាស តាមថិរវេលាខាងលើ អគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតអាចមានសិទ្ធិទទួលភារកិច្ចជំនួសបាន ដើម្បីធានាប្រក្រតីភាព ភាពជាម្ចាស់ សមិទ្ធកម្ម ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៧២ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការកំណត់តំបន់ប្រើប្រាស់ដោយចីរភាព លើផ្ទៃដីទំហំ ២៩(ម្ភៃប្រាំបួន)ហិកតា ស្ថិតនៅក្នុង ឧទ្យានជាតិកែប ភូមិសាស្ត្រសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប និងការធ្វើអនុប្បយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុប្បយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១.-**

ត្រូវបានកំណត់ជាតំបន់ប្រើប្រាស់ដោយចីរភាព ផ្ទៃដីទំហំ ២៩(ម្ភៃប្រាំបួន)ហិកតា ស្ថិតនៅក្នុងឧទ្យានជាតិកែប ភូមិសាស្ត្រសង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប ដូចមានផែនទី និងនិយាមកាភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ សម្រាប់ផ្តល់ជូនក្រុមហ៊ុន វ៉ាន់ ម៉រ (ONE MORE Ltd.) ដើម្បីបន្តរៀបចំបំពេញបែបបទនីតិវិធី ជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២.-**

ត្រូវបានធ្វើអនុប្បយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ផ្ទៃដីទំហំ ២៩(ម្ភៃប្រាំបួន)ហិកតា ដូចមានក្នុងមាត្រា១នៃអនុក្រឹត្យនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ក្រោមលក្ខខណ្ឌជួលឱ្យក្រុមហ៊ុន វ៉ាន់ ម៉រ (ONE MORE Ltd.) សម្រាប់វិនិយោគលើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ ដែលត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ និងមានកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាជ្ញាធរ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកែបត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃសុក្រ ៧ កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៤៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការធ្វើអនុបយោគប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញលិខិតលេខ ៩៦៣ សជណ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ ._**

ត្រូវបានធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីអភិវឌ្ឍជាកំពង់ផែទេសចរណ៍ឯកជនខ្នាតតូច និងភោជនីយដ្ឋាន ត្រង់ទីតាំងនៃសណ្ឋាគារ សាម៉ានេអា ប៊ិចរីសត អេនស្ប៉ា ( SAMANEA BEACH RESORT AND SPA ) នូវទីតាំងដូចខាងក្រោម÷

- ទីតាំងទី១: ដីស្ងួតច្បារទំហំ ១៣ ៣២១ ម៉ែត្រក្រឡា និងទីតាំងដីឆ្នេរទំហំ ៧ ៦៥៥ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។
- ទីតាំងទី២: ដីស្ងួតច្បារទំហំ ៩ ៩៧៤ ម៉ែត្រក្រឡា និងទីតាំងដីឆ្នេរទំហំ ៦ ១៥១ ម៉ែត្រក្រឡា ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។

**មាត្រា២._**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចាត់ចែងចុះទីតាំងធ្វើអនុបយោគដូចមានចែងក្នុងប្រការ ១ ទៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងចុះបញ្ជីជាអាជ្ញាធរមានអាណាត្តិកាន់កាប់ដីរដ្ឋ។

**មាត្រា៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៤._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកែប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៥ កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ពស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៥៥ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/៨៣៩ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីលក្ខន្តិកៈដោយឡែក ក្របខណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម នៃអាជ្ញាធរសវនកម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ

## សម្រេច

**មាត្រា ១ ..** តែងតាំងមន្ត្រីរាជការចំនួន ០២ រូប នៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់សវនកម្ម របស់អាជ្ញាធរសវនកម្មជាតិ ដូចមានរាយនាមខាងក្រោមៈ

១-លោក **សាន ទិសាល** ជាប្រធាននាយកដ្ឋានសវនកម្មទី២ ជំនួសលោកស្រី **នៃ សុខគា** ដែលត្រូវបានទទួលភារកិច្ចថ្មី

២-កញ្ញា **គង់ លក្ខិណា** ជាប្រធាននាយកដ្ឋានសវនកម្មទី១ ជំនួសលោកស្រី **អ៊ុំ សាម៉ាដែត** ដែលត្រូវបានទទួលភារកិច្ចថ្មី។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១០ រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៨៦...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិដល់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១ :** ដំឡើងថ្នាក់ដល់មន្ត្រីរាជការ ចំនួន **១៨៧រូប** នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល **សម្រាប់ឆ្នាំ២០២២** ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ឃុត ចាន់ដារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២- | ឯកឧត្តម | **តាំង សាមឿន** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣- | ឯកឧត្តម | **អេត និត** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤- | ឯកឧត្តម | **ទេព ឈុនណារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥- | លោក | **ស៊ន ពិសិដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |

| | | | | |
|---|---|---|---|---|
| ៦- | លោក | **យឹម រ៉ូឡី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៧- | លោកស្រី | **ហៀង ពីរ៉ែន** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៨- | លោក | **គួច សំបូរ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៩- | លោក | **រស់ ច័ន្ទពិសី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១០- | លោក | **ខៀវ តារ៉ាដេត** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១១- | លោក | **តាត ប៊ុននី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១២- | លោកស្រី | **ម៉ែត សុថា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៣- | លោក | **ប្រាក់ សុជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៤- | លោក | **គុយ សូនី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៥- | លោក | **គី គាងសេង** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៦- | លោកស្រី | **មុំ សុគន្ធា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៧- | លោក | **សុខ សុធន** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៨- | លោក | **គុណា ពេជ្រយ៉ាតសេន** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ១៩- | លោក | **ហុង វណ្ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២០- | លោក | **អងរី ពេជ្រមង្សា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២១- | លោក | **ទូន ច័ន្ទបញ្ញា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២២- | លោក | **ដោរ ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៣- | លោក | **ប៉ាង សុខា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៤- | លោក | **ម៉ារ៉ា សុភ័ក្ត** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៥- | លោកជំទាវ | **ស្វាយ ណាគ្រី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៦- | លោកស្រី | **ស៊ីម រ័ត្នថា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៧- | លោកស្រី | **កែវ សូនី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៨- | លោក | **ឌិន ម៉េងឆាយ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ២៩- | លោកជំទាវ | **ហ្វូត លីដា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣០- | ឯកឧត្តម | **ម៉ិច ណាវី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣១- | លោកជំទាវ | **ស៊ុន សុគន្ធមាលា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣២- | ឯកឧត្តម | **យូឃាង ថាវរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៣- | ឯកឧត្តម | **ពិន សុធា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៤- | លោក | **អៀង រដ្ឋា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៥- | ឯកឧត្តម | **ផល សុជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៦- | លោកស្រី | **ហេង ទេវី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៧- | លោក | **ស៊ូ ច័ន្ទគ្រីស្នា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៨- | លោក | **ចន សារណា:** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៣៩- | លោក | **កែវ សុវណ្ណារី** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤០- | ឯកឧត្តម | **រស់ សុវណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤១- | លោក | **ខន ដានិត** | ពីវរមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |

| | | | | |
|---|---|---|---|---|
| ៤២- | លោកស្រី | **ទេព ផារ៉េត** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៣- | លោក | **ប៉ែន ជីវ័ន្តនរី** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៤- | លោក | **សំ ស៊ីណា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៥- | លោក | **មុំ ភាម៉ុល** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៦- | លោក | **គៀ គឹមហុង** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៧- | លោកជំទាវ | **ឆាំ ម៉ារី** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៨- | លោក | **ឃាំង ឆាយ** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៤៩- | លោក | **នូ សាវុធឌី** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥០- | លោក | **កែវ លីណែត** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥១- | លោក | **ហៀង លាងហុង** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥២- | លោក | **ឯម សុវណ្ណារ៉ា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៣- | លោកស្រី | **ហាង លក្ខិណា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៤- | លោក | **ឡុង សុរិន** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៥- | លោកស្រី | **អ៊ុង ម៉ាល័យ** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៦- | លោក | **ប្រែង ពិសិដ្ឋ** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៧- | លោក | **គឹម វុទ្ធី** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៨- | លោក | **ហួត រ៉ា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៥៩- | លោក | **ប៉ាង រតនា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦០- | លោក | **ហៃ សុគន្ធា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦១- | លោក | **អ៊ុន សុភ័ក្ត្រ** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦២- | លោក | **ប៉ាង ចាន់ថា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦៣- | លោកស្រី | **ម៉ុល វាសនា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦៤- | លោក | **សួន សុភា** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦៥- | លោកស្រី | **អ៊ិត សុប៉ុញ្ញ** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦៦- | លោក | **សុខ សុភ័ក្ត** | ពីវមន្ត្រី ថ្នាក់លេខ២ | មកជាថ្នាក់លេខ១ |
| ៦៧- | ឯកឧត្តម | **ម៉ម អំណាត់** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៦៨- | ឯកឧត្តម | **គឹម សុវណ្ណា** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៦៩- | ឯកឧត្តម | **ហួ វង្សវឌ្ឍនៈ** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧០- | ឯកឧត្តម | **មាស វិបុល** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧១- | លោកស្រី | **ជិន សាវី** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧២- | លោក | **ខូយ ច័ន្ទភក្កដា** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧៣- | លោក | **អ៊ឹម ចាន់វណ្ណស្លុង** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧៤- | លោក | **គុំ ណារីម** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧៥- | លោក | **ពៅ ចាន់បូផល** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧៦- | លោក | **ឡៀង អរុណា** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧៧- | លោក | **ណី វណ្ណារិទ្ធ** | ពីវមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |

| | | | | |
|---|---|---|---|---|
| ៧៨- | លោកស្រី | **ហ៊ុយ ច័ន្ទសោភា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៧៩- | លោក | **ឈាង ឈីវហួត** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨០- | លោក | **ណៃត ម៉ិនឈាង** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨១- | លោក | **លឿង សុភ័ក្ត** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨២- | លោក | **អ៊ឹម សុភ័ណ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៣- | លោកស្រី | **លឹម សុគន្ធា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៤- | លោកស្រី | **លឹម ស្រីណិត** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៥- | លោក | **ប្រាក់ សុភា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៦- | ឯកឧត្តម | **ឆាំង ហ៊ុយ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៧- | លោក | **ច្រឹង វណ្ណី** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៨- | លោកស្រី | **លឹម ភិត្យា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៨៩- | លោក | **អ៊ុត សំអ៊ាត** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩០- | លោក | **លី សុធី** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩១- | លោកស្រី | **នេត ឈុននី** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩២- | លោក | **គង់ វីរៈ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៣- | លោកស្រី | **ផៀម កល្យាណា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៤- | លោកស្រី | **ជា សុមាលីណា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៥- | លោក | **ជិន សុសម្ផស្ស** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៦- | លោក | **អ៊ូម ចាន់ភក្តី** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៧- | លោក | **ញ៉ែម ធុល** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៨- | លោក | **ហៃ សុខាណា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ៩៩- | លោក | **ជា វិច្ឆិកា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០០- | លោក | **សួង សុផល** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០១- | ឯកឧត្តម | **ម៉ា នរិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០២- | លោកស្រី | **មាស ផល្លា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៣- | លោក | **ស្រ៊ី ប៊ូរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៤- | លោកស្រី | **ច័ន្ទ សោភ័ណា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៥- | លោកស្រី | **ឆឹង សារិនដា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៦- | លោក | **ហុង អ៊ួនអុង** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៧- | លោក | **ម៉ក់ ស៊ីថា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៨- | លោក | **នេត សុធារៈ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១០៩- | លោក | **លី សុខសុធា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១០- | លោក | **ភុល ប៊ូរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១១- | លោក | **ប៊ុត សុផា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១២- | លោក | **ទុំ ដាវីដ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១៣- | លោក | **ចាន់ ពិសិដ្ឋ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |

| | | | | |
|---|---|---|---|---|
| ១១៤- | លោកស្រី | **គិច ចាន់សុធី** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១៥- | លោក | **ព្រាប រដ្ឋា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១៦- | លោក | **ឈន ម៉ិនឆាយ** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១៧- | ឯកឧត្តម | **ស្រ៊ាង ចិន្តា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១៨- | ឯកឧត្តម | **ទិត សុធា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១១៩- | លោក | **ញ៉ៀត ចាន់** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២០- | លោក | **សោ ទេពសុបុត្ត** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២១- | លោក | **សម្បត្តិ សុបញ្ញា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២២- | លោក | **លឹម សុក្រាត** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២៣- | លោក | **ហេង សុតី** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២៤- | លោក | **អាន យ៉ុម** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២៥- | លោកស្រី | **លន ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៣ | មកជាថ្នាក់លេខ២ |
| ១២៦- | លោកជំទាវ | **ឈី ទិដ្ឋរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១២៧- | ឯកឧត្តម | **ម៉ៅ ទិបុល** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១២៨- | ឯកឧត្តម | **រស្មី ឧត្តម** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១២៩- | លោក | **ហេង សុខណា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣០- | ឯកឧត្តម | **ទី ជាតិទិសុទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣១- | លោក | **សែម សម** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣២- | លោក | **ស្រេង ហ៊ុន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៣- | ឯកឧត្តម | **ស្វាយ ដួត** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៤- | លោកស្រី | **អេន លីនណា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៥- | លោក | **អែម ម៉ាឌី** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៦- | លោក | **ខឹម ផល្លា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៧- | លោក | **សុខ ទីរៈយ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៨- | លោក | **ម៉ៅ សុផាន់ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៣៩- | លោក | **ធឿន វណ្ណះ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤០- | លោក | **អៀម សុភ័ណ្ឌ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤១- | លោកជំទាវ | **ហ៊ាន ប៉ូលីណោ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤២- | លោក | **ប៉ា ប៉ុណ្ណារ៉ាដា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៣- | លោក | **អ៊ីវ រ៉េត** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៤- | លោក | **ណាន វាសនា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៥- | លោក | **វិសិដ្ឋ សុវត្ថិ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៦- | លោក | **ជា មុនីរ័ត្ន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៧- | ឯកឧត្តម | **ហាក់ សុខហេង** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៨- | ឯកឧត្តម | **មាស បូរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៤៩- | លោក | **ដួង សុផល** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |

| | | | | |
|---|---|---|---|---|
| ១៥០- | លោក | **ហេង គីមគួ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥១- | លោក | **ជឹម ច័ន្ទស៊ីដេត** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥២- | ឯកឧត្តម | **ម៉ៅ ប៊ុនញ្ញាត្ត** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៣- | លោក | **នី ញ៉ូ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៤- | លោក | **ហ៊ាន គីមស៊ីន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៥- | លោក | **អ៊ុយ សែន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៦- | ឯកឧត្តម | **ប្រាក់ គីមហុង** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៧- | ឯកឧត្តម | **សៀក ទិចិត្រ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៨- | លោក | **អែម សំណាង** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៥៩- | លោក | **ម៉ៅ សៅហាន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦០- | លោក | **គ្រឹម សត្យា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦១- | លោក | **ហេង សេរីម៉េង** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦២- | លោក | **ស៊ិន សុធា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៣- | លោក | **ហាច់ ផល្លា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៤- | លោក | **ម៉ី ភាទី** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៥- | លោក | **ប៉ែន មករា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៦- | លោក | **សេង ដារ៉ាវុធ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៧- | លោក | **ទេព កល្យាណា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៨- | លោក | **ចាន់ ឌីម៉ា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៦៩- | លោក | **ឌួន ណារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧០- | លោកស្រី | **សុវណ្ណារ៉ា ប៉ារ៉ូនី** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧១- | លោកស្រី | **គេង ស្រីទីន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧២- | លោក | **លី ហ្សុះរី** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៣- | លោកស្រី | **ពៅនី សុខនាង** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៤- | លោកស្រី | **ញ៉ែម សុជាតា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៥- | លោក | **ហេង ស៊ីនេន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៦- | លោក | **ជឹម ធឿន** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៧- | លោក | **នាង កណ្ណិកា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៨- | លោក | **ឈុន ឆាយា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៧៩- | លោក | **សេង សុផាត** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨០- | លោក | **សំរិទ្ធ សុជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨១- | លោក | **នាង សុជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨២- | លោក | **រ៉េត ជូឡុង** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨៣- | ឯកឧត្តម | **សេដ្ឋា វឌ្ឍនា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨៤- | លោក | **ចៅ សិទ្ធិគុណា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨៥- | លោក | **ស្វាយ ចាន់មុនី** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |

| | | | | |
|---|---|---|---|---|
| ១៨៦- | លោកស្រី | **សំរិទ្ធ ចរិយា** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣ |
| ១៨៧- | លោក | **ហេង ម៉ិនសុខ** | ពីវរមន្ត្រី ថ្នាក់លេខ៤ | មកជាថ្នាក់លេខ៣។ |

**មាត្រា២ :** ដំឡើងឋានន្តរស័ក្តិដល់មន្ត្រីរាជការ ចំនួន **៥១រូប** នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល **សម្រាប់ឆ្នាំ២០២២** ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោកជំទាវ | **ឆេង សុផារី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២- | លោកស្រី | **ឈួន រតនា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣- | លោក | **នង ចាន់ថុល** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤- | លោកស្រី | **សម ពេជ្របញ្ញា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៥- | ឯកឧត្តម | **ឆេង ស៊ីថា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៦- | លោកជំទាវ | **ប៉ែន ច័ន្ទដាវី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៧- | លោក | **ធិន ភិរុណា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៨- | លោក | **ស៊ីម វិសេស** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៩- | លោក | **ថុន ថៃ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១០- | លោកស្រី | **មូល ស្រីវណ្ណា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១១- | លោកស្រី | **ជា ផល្លីន** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១២- | លោក | **អាន ថាវ៉ូខ្សេតា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៣- | លោក | **ចោង វិមាន** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៤- | លោក | **មុត ខ្វាន់សំអាតវាសនា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៥- | លោក | **ម៉ារ៉ា ដូណា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៦- | លោក | **ទូ បុណ្ណាភក្តី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៧- | លោក | **ខុយ សត្យា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៨- | លោកស្រី | **ឈឹម សោភណ្ណារី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ១៩- | លោកស្រី | **ភេនធី វីរៈយុទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២០- | លោក | **វ៉ាន់ថន ថានវ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២១- | ឯកឧត្តម | **ព្រំ សេរីឧត្តម** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២២- | ឯកឧត្តម | **មល់ វឿបសីហា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៣- | លោក | **យ៉េង យាប** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៤- | លោកស្រី | **ភេត ផាន់ណារី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៥- | លោក | **ហួន ស៊ីន** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៦- | លោក | **សំ ពៅ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៧- | លោក | **ឃួរ ប៊ុននី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៨- | លោក | **ហឿន មុំ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ២៩- | លោក | **សាយ ភីរុណា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣០- | លោកស្រី | **ស៊ិន សុភាព** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣១- | លោក | **អាំង ហ៊ីត** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣២- | លោក | **ហាខ្យ វីរៈភាព** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |

| | | | | |
|---|---|---|---|---|
| ៣៣- | លោក | **លី ភុម្គៈ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣៤- | លោក | **ហាក់ ស៊ីណា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣៥- | លោក | **តី សុតា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣៦- | លោក | **ឆាយ ពិសិដ្ឋ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣៧- | លោកស្រី | **គង់ មុនិតា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣៨- | លោក | **រ៉ា វ៉ាន់ថា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៣៩- | លោក | **លី ហ្សះរី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤០- | លោក | **ហេង ដារិទ្ធ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤១- | លោក | **សន សារ៉េត** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤២- | លោក | **អ៊ិន ប៊ុនលាប** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៣- | លោកស្រី | **ញ៉ៀម ម៉ាលីដា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៤- | លោកស្រី | **គង់ ធីឡឿន** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៥- | លោក | **ហេង ប៊ុនឡាយ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៦- | លោក | **គង់ សំអាន** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៧- | លោក | **មូ សារ៉ាវឌ្ឍ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៨- | លោក | **ស៊ឹម លាភ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៤៩- | លោក | **ពៅ សាវុធ** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៥០- | លោក | **ចាន់ វណ្ណី** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤ |
| ៥១- | លោក | **ស្រី សីហា** | ពីអនុមន្ត្រី ថ្នាក់លេខ១ | មកជាវរមន្ត្រី ថ្នាក់លេខ៤។ |

**មាត្រា៣** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១០ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៩៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** ៖ ដំឡើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **ប៉ែន សារ៉ាន់** អត្តលេខ ៣៨៦៩៦

២- វរសេនីយ៍ទោ **អៀម សារិទ្ធ** អត្តលេខ ៣៨៦៩៨

៣- វរសេនីយ៍ទោ **ម៉ួន ចន្ថា** អត្តលេខ ៣៨៩៥៧

៤- វរសេនីយ៍ទោ **ស្នួន សុភាន** អត្តលេខ ៣៨៩៥៨

៥- វរសេនីយ៍ទោ **ឯក តារាមុន្នី** អត្តលេខ ៣៨៩៦១

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃច័ន្ទ ១០ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ** : ៦៨៨.អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១** : តែងតាំងលោក **ហួរ គីមហៀង** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានប្រជាជន និងអភិវឌ្ឍ របស់ក្រសួងផែនការ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃ ចន្ទ ១០ រោច ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦*

*ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៥៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **នូ សុខណ្ណារ៉ា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ពីអភិបាល នៃគណៈអភិបាលក្រុងតាខ្មៅ ឱ្យទៅបម្រើការងារនៅរដ្ឋបាលខេត្តកណ្តាល។

**មាត្រា ២ :** តែងតាំងលោក **ឃឹម សំអារ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ឱ្យទៅកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលក្រុងតាខ្មៅ ខេត្តកណ្តាល។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៩០ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការតែងតាំង និងផ្ដល់ឋានៈទីប្រឹក្សា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២១៤ / ១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការគ្រប់គ្រង និងការបើកផ្ដល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៩ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

### សម្រេច

**មាត្រា ១.-** តែងតាំង និងផ្ដល់ឋានៈជាទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០២ រូប ៖

១- លោក **ថោង ចំរើន** មានឋានៈស្មើ អគ្គនាយករង

២- លោកស្រី **ហុង សេឌី** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៥ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៦៨១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកាល់ម៉ែត**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១១/២៣៤ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការប្រែក្លាយមន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះស្ថានសាធារណៈសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

**សម្រេច**

**មាត្រា១.-**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកាល់ម៉ែតដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តមសាស្ត្រាចារ្យ | **ឈាង** | **រ៉ា** | អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត | ប្រធាន |
| ២-ឯកឧត្តម | **ហុក** | **គីមចេង** | តំណាងក្រសួងសុខាភិបាល | សមាជិក |
| ៣-ឯកឧត្តម | **សូ** | **សុខ** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

| | | | |
|---|---|---|---|
| ៤-លោក | **ឈួន សំរិទ្ធិ** | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម | **ហួត ហៃ** | តំណាងសាលារាជធានីភ្នំពេញ | សមាជិក |
| ៦-ឯកឧត្តម | **សាផុន វឌ្ឍនៈ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិកស្វ័យប្រវត្តិ |
| ៧-ឯកឧត្តមសាស្ត្រាចារ្យ | **ឱ វ៉ាន់ដា** | តំណាងមន្ត្រីរាជការ-បុគ្គលិក | សមាជិកស្វ័យប្រវត្តិ |

**មាត្រា២.-**

អនុក្រឹត្យលេខ ១០៨៤ អនក្រ/តត ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៩ ស្តីពីការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យកាល់ម៉ែត និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ សីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួងយុត្តិធម៌ចំនួន **៦៦ រូប** ដូចមានរាយនាមខាងក្រោម៖

**ក-អគ្គលេខាធិការដ្ឋាននៃក្រសួងយុត្តិធម៌**

១. លោក **ស៊ី ពិសេដ្ឋ** ជាអគ្គលេខាធិការរង

២. លោក **ស៊ឹង សារ៉ាត** ជាអគ្គលេខាធិការរង
៣. លោកស្រី **សួរ ដានី** ជាអគ្គលេខាធិការរង
៤. លោកស្រី **សារឿន សុពណ៌** ជាអគ្គលេខាធិការរង
៥. លោកស្រី **ហ៊ិន សុភាព** ជាអគ្គលេខាធិការរង
៦. លោក **ឈឹម សារ៉ែន** ជាប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក
៧. លោក **ណុប វណ្ណៈ** ជាប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ
៨. លោក **ជួន ចំរើន** ជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល
៩. លោក **ម៉ែន ចំណាន** ជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា និងបរិវត្តកម្មឌីជីថល

**ខ-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ**

១. លោក **សៀង គង់** ជាអគ្គនាយករង
២. លោក **ច័ន្ទ សត្ថា** ជាអគ្គនាយករង
៣. លោក **ជា ករុណា** ជាអគ្គនាយករង
៤. លោក **ទិត សារឿន** ជាអគ្គនាយករង
៥. លោក **កេត ស៊ីណែត** ជាអគ្គនាយករង
៦. លោក **ពៅ វិបុល** ជាប្រធាននាយកដ្ឋានកិច្ចការបច្ចេកទេស និងទំនើបកម្មរដ្ឋបាលតុលាការ
៧. លោក **យស អូន** ជាប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុនៃសាលាជម្រះក្តី
៨. លោក **ស៊ឹម ស៊ីដា** ជាប្រធាននាយកដ្ឋានគ្រប់គ្រងធនធានមនុស្សនៃរដ្ឋបាលតុលាការ
៩. លោក **ហ៊ឹម វិចតេលា** ជាប្រធាននាយកដ្ឋានអាជ្ញាសាលា
១០.លោកស្រី **ស្មាន់ វណ្ណធីតា** ជាប្រធាននាយកដ្ឋានក្រឡាបញ្ជី
១១.លោកស្រី **វ៉ាន់ យ៉ានីន** ជាប្រធាននាយកដ្ឋានកិច្ចការតម្កល់ និងផ្ញើ

**គ-អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី**

១. លោក **សេង សត្យា** ជាអគ្គនាយករង
២. លោក **សៀង ហ៊ី** ជាអគ្គនាយករង
៣. លោកស្រី **សែម សែងវថៃ** ជាប្រធាននាយកដ្ឋានកិច្ចការច្បាប់រដ្ឋប្បវេណី និងអន្តរវិស័យ
៤. លោកស្រី **សឿ ចាន់វាសនា** ជាប្រធាននាយកដ្ឋានកិច្ចការក្ស័យធន អភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជី
៥. លោក **សូ សុខហុង** ជាប្រធាននាយកដ្ឋានកិច្ចការអនុវត្តសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី
៦. លោក **សុខ បូរ៉ា** ជាប្រធាននាយកដ្ឋានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់
៧. លោក **កាន់ សុទ្ធប៉ូលីន** ជាប្រធាននាយកដ្ឋានសារការី

**ឃ-អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ**

១. លោក **នុប សុធនវិសុទ្ធ** ជាអគ្គនាយករង
២. លោកស្រី **សុន សុខាលីដា** ជាអគ្គនាយករង
៣. លោកស្រី **គា ម៉ីម៉ី** ជាអគ្គនាយករង
៤. លោក **ឡាយ លាងសេង** ជាអគ្គនាយករង

៥. លោកស្រី **សុខ វិសាល** ជាប្រធាននាយកដ្ឋានកិច្ចការអយ្យការ
៦. លោកស្រី **ប៉ែន ផល្លីកា** ជាប្រធាននាយកដ្ឋានកិច្ចការយុត្តិធម៌ព្រហ្មទណ្ឌ និងនគរបាលយុត្តិធម៌
៧. លោក **សេង ពុទ្ធី** ជាប្រធាននាយកដ្ឋានកិច្ចការច្បាប់ព្រហ្មទណ្ឌ
៨. លោកស្រី **យុន ច័ន្ទសោភា** ជាប្រធាននាយកដ្ឋានគ្រប់គ្រងវត្ថុតាង និងផលនៃបទល្មើស
៩. លោក **លី សុផាណា** ជាប្រធាននាយកដ្ឋានស្រាវជ្រាវ និងស៊ើបអង្កេត

**ង-អគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ**

១. លោក **សុច សុផាន់ណារ៉ា** ជាអគ្គនាយករង
២. លោក **ម៉េង គួង** ជាអគ្គនាយករង
៣. លោកស្រី **សរ ច័ន្ទរ៉ាត** ជាអគ្គនាយករង
៤. លោកស្រី **ផល សុភាព** ជាអគ្គនាយករង
៥. លោក **ហេង សេង** ជាប្រធាននាយកដ្ឋានកិច្ចការបណ្តឹងទោស
៦. លោកស្រី **រាម នារតី** ជាប្រធាននាយកដ្ឋានកិច្ចការអនុគ្រោះទោស
៧. លោក **យាក វិសាលរតនៈ** ជាប្រធាននាយកដ្ឋានកិច្ចការអនុវត្តទោស និងដោះលែងដោយមានលក្ខខណ្ឌ

**ច-អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌**

១. លោក **គី ខេមលីន** ជាអគ្គនាយករង
២. លោក **នាង ស៊ីណាវឌ្ឍនៈ** ជាអគ្គនាយករង
៣. លោក **លាវ ពិសិដ្ឋ** ជាអគ្គនាយករង
៤. លោក **ឃ្លោក ដារ៉ា** ជាអគ្គនាយករង
៥. លោកស្រី **ឌី ម៉ូឡានី** ជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់
៦. លោក **អ៊ុង វឌ្ឍសុរិន** ជាប្រធាននាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន
៧. លោក **ង៉ូ សាឡុង** ជាប្រធាននាយកដ្ឋានអ្នកបកប្រែ និងអ្នកជំនាញក្នុងវិស័យច្បាប់ និងយុត្តិធម៌
៨. លោកស្រី **និល ហ៊ីលីប** ជាប្រធាននាយកដ្ឋានផ្សព្វផ្សាយ និងបណ្តុះបណ្តាលច្បាប់
៩. លោកស្រី **ស៊ំរិទ្ធ កញ្ញានា** ជាប្រធាននាយកដ្ឋានស្រាវជ្រាវ និងផែនការ

**ឆ-អគ្គាធិការដ្ឋានកិច្ចការតុលាការ**

១. លោក **អួន ពិសាល** ជាអគ្គាធិការរង
២. លោក **ឡុច សុខលៀង** ជាអគ្គាធិការរង
៣. លោក **លិន សីលា** ជាអធិការ
៤. លោក **គឹម សោភ័ណ** ជាអធិការ
៥. លោក **តាន់ មុនីវណ្ណ** ជាអធិការ
៦. លោក **ឃី ឈិត** ជាអធិការ
៧. លោក **សុន ស៊ិ** ជាអធិការ
៨. លោក **សេង សុវណ្ណ** ជាអធិការ

៩. លោក **ប៊ុន ច័ន្ទកុម្ភៈ** ជាអធិការ
១០.លោកស្រី **សៀង សុខណា** ជាអធិការ
១១.លោក **អាំង ស៊ុនហុក** ជាអធិការ
១២.លោក **ហួន វណ្ណហន** ជាប្រធាននាយកដ្ឋានកិច្ចការទូទៅ
១៣.លោក **ប៉ៀត ច័ន្ទសុភា** ជាប្រធាននាយកដ្ឋានកិច្ចការបច្ចេកទេសច្បាប់ និងនីតិវិធី

**ជ-នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

១.លោកស្រី **ផាន់ ច័ន្ទលី** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦៩៣.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**មាត្រា១ :** តែងតាំងលោក **ទេព ថីរិទ្ធ** ជាទីប្រឹក្សាក្រសួងសាធារណការនិងដឹកជញ្ជូន មានឋានៈស្មើ **អគ្គនាយករង**។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦៩៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្លាស់ និងតែងតាំង មន្ត្រីការទូតជាន់ខ្ពស់ប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែប្រែ និងដំឡើងបៀវត្សប្រចាំខែ និងការឧបត្ថម្ភផ្សេងៗសម្រាប់មន្ត្រីរាជការ និងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១** : ត្រូវបានផ្លាស់ និងតែងតាំង មន្ត្រីការទូតជាន់ខ្ពស់ ប្រចាំស្ថានតំណាងកម្ពុជានៅបរទេស ដូចមានរាយនាមខាងក្រោម៖

១-**ផ្លាស់**លោក **ផន សុផល** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំចក្រភពអង់គ្លេស ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-**តែងតាំង**លោកស្រី **មាច សុនាវី** បច្ចុប្បន្នប្រធាននាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ច និងបញ្ហាសកល ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំចក្រភពអង់គ្លេស ជំនួសវិញ។

២-**ផ្លាស់**លោក **ខៃ លន** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-**តែងតាំង**លោក **គាម សារ៉ាត់** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអធិការកិច្ចរដ្ឋបាលកណ្តាល ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៏ ជំនួសវិញ។

៣- **ផ្លាស់**លោក **ម៉ូល សេខគី** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប៊ុលហ្គារី ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-**តែងតាំង**លោកស្រី **លី រតនៈ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអង្គការអន្តរជាតិ ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប៊ុលហ្គារី ជំនួសវិញ។

៤-**ផ្លាស់**លោក **ហេខ សុនា** ទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋតួកគី ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-**តែងតាំង**លោក **គាំ សារឿន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋតួកគី ជំនួសវិញ។

៥-**ផ្លាស់**លោក **ខៀវ រិទ្ធីយ៉ា** អគ្គទីប្រឹក្សា នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋស៊ែប៊ី ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-**តែងតាំង**លោកស្រី **អ៊ូ សុជាតា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានកិច្ចការទូទៅ ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋស៊ែប៊ី ជំនួសវិញ។

៦-**ផ្លាស់**លោក **សុខ សុនា** ទីប្រឹក្សា នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ចូលប្រទេស ដោយចប់អាណត្តិបេសកកម្ម។

-**តែងតាំង**លោក **ចាន់ បុណ្ណារិទ្ធិ** បច្ចុប្បន្នប្រធាននាយកដ្ឋានគោលនយោបាយ ការទូតសេដ្ឋកិច្ច និងផែនការយុទ្ធសាស្ត្រ ជា**ទីប្រឹក្សា** នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ជំនួសវិញ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៣៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា១** : តែងតាំងមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | **គឹម សុវណ្ណារ៉ា** | ប្រធាននាយកដ្ឋានរដ្ឋបាល ជា **អគ្គលេខាធិការរង** ជំនួសលោក ហួ សុផារ៉ា ដែលទទួលភារកិច្ចថ្មី |
| ២-លោក | **អៀម ពុទ្ធឫទ្ធិរោ** | អតីតអគ្គកុងស៊ុលនៅទីក្រុងគុនមិញ ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក |
| ៣-លោក | **អ៊ុំ វណ្ណថា** | អតីតអគ្គកុងស៊ុលប្រចាំទីក្រុងហៃគូ ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន |
| ៤-លោក | **ម៉ុន សុខវិបុល** | ប្រធាននាយកដ្ឋានកិច្ចការព្រំដែន ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន |
| ៥-លោក | **ជ័យ រដ្ឋា** | ប្រធាននាយកដ្ឋានកិច្ចការកុងស៊ុល ជា **អគ្គនាយករង** នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន |
| ៦-លោក | **យស សុខេមរិន** | អនុប្រធាននាយកដ្ឋាន ជា **ប្រធាននាយកដ្ឋានកិច្ចការកុងស៊ុល** នៃអគ្គនាយកដ្ឋានកិច្ចការច្បាប់ កុងស៊ុល និងព្រំដែន |
| ៧-លោក | **ស៊ឹម គីមអ៊ិច** | អនុប្រធាននាយកដ្ឋាន ជា **ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ** |
| ៨-លោក | **អ៊ុំ សុខុម** | អនុប្រធាននាយកដ្ឋានគោលនយោបាយ ការទូតសេដ្ឋកិច្ច និងផែនការយុទ្ធសាស្ត្រ ជា **ប្រធាននាយកដ្ឋានរដ្ឋបាល** ។ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ៧ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១** : ប្រគល់ភារកិច្ចជូនលោក **ឃុត ម៉ិនឈាង** ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានព័ត៌មាននៃវិទ្យាស្ថានស្តង់ដារកម្ពុជារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**មាត្រា២**: បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៨៣ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពក្រុមការងារតាមវិស័យ សម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៦ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការតាមវិស័យនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន

- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៧ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៥៣ សសរ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានតែងតាំងឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាប្រធានក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្មនៃក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយវិស័យឯកជន ជំនួសឯកឧត្តម **វេង សាខុន**។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៨៤៤ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០០ សសរ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានតែងតាំងឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិកក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល ជំនួសឯកឧត្តម **វេង សាខុន**។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៥កើត ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០២២✓

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៥៥ សហវ.ប្រក

**ប្រកាស**

**ស្ដីពី**

**ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្ដីពីនីតិវិធីអនុវត្ត**
**ថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ ២០២៣**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្ដីពីការតែងតាំង និង ការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២ ដែលប្រកាសប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ ស្ដីពីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ ២០២៣

- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុង និង ក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និង តាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- បានឃើញអនុក្រឹត្យលេខ ២២៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣
- បានឃើញអនុក្រឹត្យលេខ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៩ ស្តីពីការសម្រួលមាត្រា ២ និង មាត្រា ៧ នៃអនុក្រឹត្យលេខ ២២៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈ-កម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣
- បានឃើញលិខិតលេខ ៣៨៤ សជណ. ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការអនុញ្ញាតជាគោលការណ៍ឱ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកីឡា SEA Games នៅឆ្នាំ ២០២៣
- បានឃើញប្រកាសលេខ ៧២៦ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៩ ស្តីពីវិធាន និង នីតិវិធីអនុវត្តចំណាយមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ ២០២៣
- បានឃើញប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០២១ ស្តីពីវិធាននិងនីតិវិធីអនុវត្តចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និង សន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១._**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី នីតិវិធីអនុវត្តថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ ២០២៣ ដូចមានភ្ជាប់ជាមួយប្រកាសនេះ ។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តសម្រាប់ការគ្រប់គ្រងថវិកា និង ធនធាន នៅក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ (គ.ជ.ប.អ.) ។

**ប្រការ៣._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ (គ.ជ.ប.អ.) ប្រធានគណៈកម្មការជំនាញក្រោមចំណុះគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ី-អាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ (គ.ជ.ប.អ.) ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃចន្ទ ១២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ១២ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គណៈកម្មការជំនាញក្រោមចំណុះគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ (គ.ជ.ប.អ.)
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ណែនាំ

# ស្តីពី

# នីតិវិធីអនុវត្តថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា

# ឆ្នាំ២០២៣

ខែ វិច្ឆិកា ឆ្នាំ ២០២២

**មាតិកា** **ទំព័រ**


**ផ្នែកទី ១ សេចក្តីផ្តើម** ............................................................ ១

**ផ្នែកទី ២ រចនាសម្ព័ន្ធគ្រប់គ្រងនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២ ឆ្នាំ២០២៣** ............................................................ ២

២.១. គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ (គ.ជ.ប.អ.).... ២

២.២. យន្តការចំណុះនានា ............................................................ ២

២.២.១. គណៈកម្មការសន្តិសុខ និងសណ្តាប់ធ្នាប់ ............................................................ ២

២.២.២. គណៈកម្មការកីឡា និងបទប្បញ្ញត្តិ ............................................................ ៣

២.២.៣. គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ............................................................ ៣

២.២.៤. គណៈកម្មការហេដ្ឋព័ត៌មានវិទ្យា ............................................................ ៣

២.២.៥. គណៈកម្មការទីលានប្រកួត ............................................................ ៣

២.២.៦. គណៈកម្មការវេជ្ជសាស្ត្រ និងដូពីង ............................................................ ៣

២.២.៧. គណៈកម្មការអ្នកស្ម័គ្រចិត្ត ............................................................ ៣

២.២.៨. គណៈកម្មការវប្បធម៌ បរិស្ថាន និងអប់រំកីឡា ............................................................ ៣

២.២.៩. គណៈកម្មការស្នាក់នៅ ហូបចុក និងដឹកជញ្ជូន ............................................................ ៤

២.២.១០. គណៈកម្មការផ្សព្វផ្សាយនិងព័ត៌មាន ............................................................ ៤

២.២.១១. គណៈកម្មការទីផ្សារ និងចលនទ្រព្យ ............................................................ ៤

២.២.១២. គណៈកម្មការពិធីការ ............................................................ ៤

២.២.១៣. គណៈកម្មការពិធីបើក និងបិទ ............................................................ ៤

២.២.១៤. លេខាធិការដ្ឋាន ............................................................ ៤

**ផ្នែកទី៣ ប្រភពថវិកានិងធនធាន និងមុខសញ្ញាចំណាយ** ............................................................ ៦

៣.១. ប្រភពថវិកា និងធនធាន ............................................................ ៦

៣.១.១. ថវិការដ្ឋ ............................................................ ៦

៣.១.២. ប្រភពផ្សេងទៀត ............................................................ ៦

៣.២. មុខសញ្ញាចំណាយ ............................................................ ៦

I. ចំណាយប្រចាំ ............................................................ ៦

ក. ចំណាយលើបុគ្គលិក និងការឧបត្ថម្ភ ............................................................ ៦

ខ. ចំណាយសោហ៊ុយបេសកកម្មនៅក្នុង និងក្រៅប្រទេស ............................................................ ៧

គ. ចំណាយរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ............................................................ ៧

ឃ. ចំណាយជួលអ្នកជំនាញការ និងគ្រូបង្វឹកបរទេស ............................................................ ៧

ង. ចំណាយការងារអភិវឌ្ឍន៍បច្ចេកទេសកីឡា ............................................................ ៨

ច. ចំណាយទទួលភ្ញៀវជាតិ និងអន្តរជាតិ ............................................................ ៨

ឆ. ចំណាយផ្សព្វផ្សាយ និងព័ត៌មានវិទ្យា ............................................................ ៨

ជ. ចំណាយរៀបចំព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិ ........................................ ៨

ឈ. ចំណាយលើមធ្យោបាយដឹកជញ្ជូន ........................................ ៩

ញ. ចំណាយសម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល ........................................ ៩

ដ. ចំណាយទិញឯកសណ្ឋាន ........................................ ៩

ឋ. ចំណាយទិញឧបករណ៍ និងសម្ភារបច្ចេកទេសកីឡាស្តង់ដា ........................................ ៩

ឌ. ចំណាយបរិក្ខារនិងគ្រឿងសង្ហារិម ........................................ ៩

ឍ. ចំណាយជួសជុល និងថែទាំ ........................................ ៩

ណ. ចំណាយមិនបានគ្រោងទុក ........................................ ៩

II. ចំណាយមិនប្រចាំ ........................................ ១០

**ផ្នែកទី ៤ យន្តការនៃការទទួលខុសត្រូវលើការគ្រប់គ្រងថវិកា និងធនធានរបស់ គ.ជ.ប.អ. ............** ១០

៤.១. គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣. ................ ១០

៤.១.១. ប្រធានគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ .. ១១

៤.១.២. អគ្គលេខាធិការនៃ គ.ជ.ប.អ. ........................................ ១១

៤.១.៣. លេខាធិការនៃ គ.ជ.ប.អ. ........................................ ១១

៤.២. គណៈកម្មការជំនាញចំណុះ គ.ជ.ប.អ. ........................................ ១១

៤.២.១. គណៈកម្មការជំនាញ និងលេខាធិការដ្ឋាន ........................................ ១១

៤.២.២. គណៈកម្មការជំនាញ និងលេខាធិការដ្ឋាន........................................ ១២

៤.៣. គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា,
មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា និងសហព័ន្ធកីឡាជាតិ ........................................ ១៣

**ផ្នែកទី ៥ នីតិវិធីនៃការគ្រប់គ្រងថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ......................** ១៥

៥.១ គោលការណ៍រួមសម្រាប់ការគ្រប់គ្រងថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ ២០២៣ ......... ១៥

៥.២ ការកសាងផែនការថវិកា និងធនធានសម្រាប់ គ.ជ.ប.អ. ........................................ ១៦

៥.២.១. សារសំខាន់នៃការកសាងផែនការ ........................................ ១៦

៥.២.២. ក្របខ័ណ្ឌពេលវេលា ........................................ ១៦

៥.២.៣. មូលដ្ឋាននៃការកសាងផែនការ ........................................ ១៦

៥.២.៤. យន្តការនៃការទទួលខុសត្រូវ ........................................ ១៦

៥.២.៥. បរិបថការងារ ........................................ ១៧

៥.៣ ការអនុវត្តចំណាយថវិកា និងការប្រើប្រាស់ធនធានរបស់ គ.ជ.ប.អ. ........................................ ១៩

៥.៣.១. ចំណាយតាមគោលរបប និងចំណាយតាមសក្ខីបត្រ ........................................ ១៩

៥.៣.២. ចំណាយតូចតាច ........................................ ២០

៥.៣.៣. ចំណាយជាកម្មវត្ថុនៃកិច្ចលទ្ធកម្ម ........................................ ២១

៥.៤. ការគ្រប់គ្រងចំណូល ........................................ ២៥

**ផ្នែកទី៦ ការគ្រប់គ្រងឃ្លាំង សន្និធិ និងទ្រព្យសម្បត្តិ ........................................** ២៥

៦.១. ការគ្រប់គ្រងឃ្លាំង និងសន្និធិ ........................................ ២៥

៦.១.១. អំពីឃ្លាំង ........ ២៥
៦.១.២. អំពីសន្និធិ ........ ២៥
៦.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ ........ ២៦
**ផ្នែកទី៧ របបរបាយការណ៍** ........ ២៧
៧.១. របាយការណ៍អនុវត្តថវិកា ........ ២៧
៧.១.១. របាយការណ៍ចំណូល-ចំណាយថវិកា ........ ២៨
៧.១.២. របាយការណ៍លទ្ធផល ........ ២៨
៧.២. របាយការណ៍សន្និធិ ........ ២៨
៧.៣. របាយការណ៍ទ្រព្យសម្បត្តិ ........ ២៨
**ផ្នែកទី ៨ ការត្រួតពិនិត្យ និងសវនកម្ម** ........ ២៨
**ឧបសម្ពន្ធ** ........ ២៩-៣០

**ផ្នែកទី ១ សេចក្តីផ្តើម**

ព្រះរាជាណាចក្រកម្ពុជានឹងទទួលធ្វើជាម្ចាស់ផ្ទះនូវព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ ដែលជាលើកទីមួយ និងជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបង្ហាញពិភពលោកនូវវប្បធម៌ អរិយធម៌ ទេសចរណ៍ សេដ្ឋកិច្ច និងសង្គមដ៏រីកចម្រើនបច្ចុប្បន្ន ហើយនេះក៏ជាសមិទ្ធផលមួយដែលកើតឡើងផងក្រោមការដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវនិងឈ្លាសវៃរបស់ប្រមុខរាជរដ្ឋាភិបាល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលធ្វើឱ្យវិស័យកីឡារបស់ព្រះរាជាណាចក្រកម្ពុជាប្រែមុខមាត់ថ្មីទាំងនៅលើឆាកជាតិ ទាំងឆាកអន្តរជាតិ ។

ដើម្បីអនុវត្តនូវផែនការមេឆ្ពោះទៅកាន់ការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី ៣២ ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវ **មូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣** ដើម្បីគ្រប់គ្រងថវិកាវិភាគទានរបស់រាជរដ្ឋាភិបាលសម្រាប់ការរៀបចំព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ដោយបានអនុញ្ញាតឱ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកពិនិត្យ និងសម្រេចលើការបើកផ្តល់ថវិកាមូលនិធិ ព្រមទាំងរៀបចំនីតិវិធីអនុវត្តថវិកាសម្រាប់មូលនិធិ ។ ក្នុងន័យនេះ ដោយឈរលើយុទ្ធសាស្ត្រ **«សន្សំសំចៃ ប៉ុន្តែផ្តល់នូវការប្រកួតដ៏អស្ចារ្យ»** សម្រាប់ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ នៅព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដាក់ចេញនូវគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ ២០២៣នេះ ដោយមានទស្សនវិស័យច្បាស់លាស់ គឺ ឆ្លើយតបឱ្យមានប្រសិទ្ធភាពទៅនឹងស្ថានភាពជាក់ស្តែង និងធានាប្រសិទ្ធភាព ភាពសន្សំសំចៃ និងភាពជោគជ័យ ទាំងនៅក្នុងពេលត្រៀមខ្លួន ទាំងនៅក្នុងអំឡុងពេលឆ្នាំព្រឹត្តិការណ៍នៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ នៅព្រះរាជាណាចក្រកម្ពុជា ។

ការធ្វើជាម្ចាស់ផ្ទះនៃការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ តម្រូវឱ្យមាននូវយន្តការដែលអាចប្រើប្រាស់កម្លាំងសរុប និងមធ្យោបាយសរុប ដើម្បីធ្វើសកម្មភាពប្រកបដោយភាពប្រទាក់ក្រឡារវាងវិស័យពាក់ព័ន្ធរួមមាន៖ និយតករកីឡាដែលមានក្រសួងអប់រំ យុវជន និងកីឡាជាសេនាធិការរបស់រាជរដ្ឋាភិបាល, គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិក, មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា, សហព័ន្ធកីឡាជាតិ, អាជ្ញាធរមានសមត្ថកិច្ច និងវិស័យឯកជន ។ ដូច្នេះ ដើម្បីឱ្យការរៀបចំព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះទទួលបានជោគជ័យ, យន្តការថ្មីនេះ ត្រូវការជាចាំបាច់នូវថវិកា និងធនធានជាសម្ភារ ឧបករណ៍ និងមធ្យោបាយគ្រប់គ្រាន់ និងទាន់ពេលវេលា ។ ឈរលើស្មារតីនេះ គោលការណ៍ណែនាំស្តីពីស្តីពីនីតិវិធីអនុវត្តថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ២០២៣ នេះមានគោលដៅសម្រួលដល់ការអនុវត្តចំណាយថវិកា ដោយកាត់បន្ថយបែបបទនិងនីតិវិធីគ្រប់គ្រងថវិកាឱ្យនៅខ្លី និងសាមញ្ញ ។ គោលបំណងសំខាន់នៃគោលការណ៍ណែនាំនេះគឺ ដើម្បីធានាឱ្យការបើកផ្តល់ថវិកា ក៏ដូចជាការផ្គត់ផ្គង់ធនធានជាសម្ភារ ឧបករណ៍ និងមធ្យោបាយសម្រាប់ការត្រៀមខ្លួន ក៏ដូចជាការរៀបចំព្រឹត្តិការណ៍ប្រកួត បានគ្រប់គ្រាន់ ទាន់ពេលវេលា ចំគោលដៅ និងមិនខ្ចះខ្ចាយ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពច្បាស់លាស់ ។

**ផ្នែកទី ២ រចនាសម្ព័ន្ធគ្រប់គ្រងនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣**

យោងអនុក្រឹត្យលេខ២២៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣, និងអនុក្រឹត្យលេខ ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា២ និងមាត្រា៧ នៃអនុក្រឹត្យលេខ២២៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ហៅកាត់ថា **គ.ជ.ប.អ.** ឬ សរសេរកាត់ជាភាសាអង់គ្លេសថា CAMSOC ត្រូវបានបង្កើតឡើងដើម្បីជាយន្តការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ (SEA Games) លើកទី ៣២ ឆ្នាំ២០២៣ ដែលព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួត ។ ជាមួយគ្នានេះ បទដ្ឋានគតិយុត្តមួយចំនួនទៀតពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ក៏ត្រូវបានបង្កើតឡើង ដូចមាននៅក្នុងឧបសម្ព័ន្ធទី ២ ។

**២.១. គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ (គ.ជ.ប.អ.)**

គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ បំពេញការងាររបស់ខ្លួនក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិដែលជាប្រធាន មានឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអនុប្រធាន និងមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាជាអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងមានរដ្ឋមន្ត្រី ប្រធានស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធជាសមាជិក ។ គ.ជ.ប.អ. មានអគ្គលេខាធិការដ្ឋានដែលមានអគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ជាអគ្គលេខាធិការ និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួនជាអគ្គលេខាធិការរង ។

គ.ជ.ប.អ. មានតួនាទីជាអាទិ៍ ដឹកនាំ គ្រប់គ្រង និងរៀបចំការប្រកកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការមេ និងផែនការសកម្មភាពតាមដំណាក់កាលរបស់គណៈកម្មការជំនាញក្រោមឱវាទ ព្រមទាំងធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋ អាជ្ញាធរ និងអង្គការកីឡាជាតិ វិស័យឯកជន អាជ្ញាធរកីឡា គណៈកម្មាធិការជាតិអូឡាំពិកបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ សកលលោក និងជាមួយចលនាអូឡាំពិកអន្តរជាតិ ដើម្បីឆ្ពោះទៅរកប្រសិទ្ធភាពនៃដំណើរការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ ។ គ.ជ.ប.អ. ក៏មានភារកិច្ចក្នុងការកៀរគរធនធានហិរញ្ញវត្ថុនិងជំនួយផ្សេងៗពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ផងដែរ ។

**២.២. យន្តការចំណុះនានា**

គ.ជ.ប.អ. មានគណៈកម្មការចំណុះចំនួន ១៤ ដូចខាងក្រោម ÷

**២.២.១. គណៈកម្មការសន្តិសុខ និងសណ្ដាប់ធ្នាប់**

គណៈកម្មការសន្តិសុខ និងសណ្ដាប់ធ្នាប់ មានតួនាទី និងភារកិច្ច ជាអាទិ៍រៀបចំផែនការ ការពារ បង្ការ ទប់ស្កាត់រាល់វិទ្ធង្សនាប្រឆាំងនឹងការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣, ត្រូវការពារសន្តិសុខសុវត្ថិភាព រៀបរៀបរយរាល់កម្មវិធីរបស់ គ.ជ.ប.អ. មុនព្រឹត្តិការណ៍ប្រកួត អំឡុងពេលប្រកួត និងក្រោយការប្រកួត ព្រមទាំងរៀបចំផែនការសុវត្ថិភាពចរាចរណ៍ សុវត្ថិភាពរបស់ប្រតិភូកីឡា និងទីលានប្រកួត ។

**២.២.២. គណៈកម្មការកីឡា និងបទប្បញ្ញត្តិ**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំប្រភេទកីឡា វិញ្ញាសាកីឡា និងសៀវភៅបច្ចេកទេស រៀបចំប្រជុំជាមួយបណ្តាប្រទេសជាសមាជិកសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ក្នុងការកំណត់ប្រភេទកីឡា និងវិញ្ញាសាកីឡា ។ ទន្ទឹមនឹងនេះ គណៈកម្មការនេះត្រូវរៀបចំមន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ចៅក្រម ជាមួយសហព័ន្ធកីឡាជាតិ សហព័ន្ធកីឡាអន្តរជាតិ ថ្នាក់តំបន់ ទ្វីប និងពិភពលោក ។

**២.២.៣. គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍រៀបចំគម្រោងផែនការហិរញ្ញវត្ថុ គ្រប់គ្រងសាច់ប្រាក់ ចំណូល និងចំណាយ គ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ និងបញ្ជីសារពើភណ្ឌគ្រប់ប្រភេទរបស់ គ.ជ.ប.អ. និងត្រូវរៀបចំគោលការណ៍ និងនីតិវិធីអនុវត្តចំណាយស្របតាមនីតិវិធីហិរញ្ញវត្ថុ និងព្រមទាំងរៀបចំត្រួតពិនិត្យយុទ្ធសាស្ត្រនិងផែនការកៀរគរចំណូល បានពីការធ្វើសកម្មភាពទីផ្សារ ចលនទ្រព្យ ការលក់សំបុត្រ ការបង់ថ្លៃចូលរួមរបស់ប្រតិភូកីឡា និងប្រភពចំណូលផ្សេងៗទៀត ។

**២.២.៤. គណៈកម្មការហេដ្ឋព័ត៌មានវិទ្យា**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍រៀបចំផែនការដំឡើងកម្មវិធីបញ្ចូលទិន្នន័យកីឡា អភិវឌ្ឍកម្មវិធីលទ្ធផលប្រកួតបម្រើឱ្យការងារគ្រប់គ្រងស្ថិតិចុះឈ្មោះ និងកម្មវិធីលទ្ធផលប្រកួត កម្មវិធីប្រកួត តារាងមេដាយ និងការងារពាក់ព័ន្ធ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ។

**២.២.៥. គណៈកម្មការទីលានប្រកួត**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍រៀបចំផែនការប្រើប្រាស់ទីលានប្រកួតគ្រប់ប្រភេទកីឡា និងរៀបចំទីកន្លែងសម្រាប់អ្នកពាក់ព័ន្ធ ។

**២.២.៦. គណៈកម្មការវេជ្ជសាស្ត្រ និងដូពីង**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំផែនការថែរក្សាសុខភាព ពិនិត្យព្យាបាលគ្រប់ទីលានប្រកួត កន្លែងស្នាក់នៅ និងហូបចុក បង្កើតមណ្ឌលសុខភាពក្នុងភូមិកីឡា និងរថយន្តគ្លីនិកចល័ត រថយន្តសង្គ្រោះបន្ទាន់ ។ ទន្ទឹមនឹងនេះ គណៈកម្មការនេះត្រូវរៀបចំផែនការធ្វើតេស្តពិនិត្យដូពីង ដោយសហការជាមួយស្ថាប័នកីឡាអន្តរជាតិ និងត្រូវធ្វើផែនការផ្សព្វផ្សាយច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងសារធាតុដូពីងក្នុងកីឡា និងកម្មវិធីធ្វើតេស្តជាដើម ។

**២.២.៧. គណៈកម្មការអ្នកស្ម័គ្រចិត្ត**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍រៀបចំផែនការជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តតាមចំនួនដែលបានកំណត់ និងបែងចែកភារកិច្ចឱ្យអ្នកស្ម័គ្រចិត្តទៅតាមមុខងារដែលត្រូវទទួលបន្ទុក ។

**២.២.៨. គណៈកម្មការវប្បធម៌ បរិស្ថាន និងអប់រំកីឡា**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំផែនការសកម្មភាពវប្បធម៌ បរិស្ថាន និងអប់រំកីឡា ដោយផ្តោតការយកចិត្តទុកដាក់លើយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈលើប្រធានបទ Power of the SEA Games ឆ្នាំ ២០២៣ និងផ្សព្វផ្សាយព្រឹត្តិការណ៍ទាក់ទាញទេសចរណ៍ ។

**២.២.៩. គណៈកម្មការស្នាក់នៅ ហូបចុក និងដឹកជញ្ជូន**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំទីកន្លែងស្នាក់នៅ បន្ទប់ស្នាក់នៅ និងកន្លែងអាហារ រៀបចំម្ហូបអាហារនៅតាមកន្លែងស្នាក់នៅ រៀបចំការដឹកជញ្ជូន ប្លង់ផែនទីផ្លូវធ្វើដំណើរ មធ្យោបាយដឹកជញ្ជូន និងសម្របសម្រួលការដឹកជញ្ជូន ។

**២.២.១០. គណៈកម្មការផ្សព្វផ្សាយនិងព័ត៌មាន**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំផែនការផ្សព្វផ្សាយ និងរៀបចំប្រព័ន្ធព័ត៌មានឱ្យបានទូលំទូលាយ រៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំអត្ថប្រយោជន៍កីឡា អត្ថប្រយោជន៍កីឡាស៊ីហ្គេម សម្រាប់ម្ចាស់ផ្ទះ ។ ទន្ទឹមនឹងនេះ គណៈកម្មការនេះត្រូវរៀបចំជ្រើសរើសក្រុមហ៊ុនផ្សព្វផ្សាយជំនាញឯកទេសកីឡា និងរៀបចំកម្មវិធីពេលព្រឹត្តិការណ៍ប្រកួត ។

**២.២.១១. គណៈកម្មការទីផ្សារ និងចលនទ្រព្យ**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំផែនការយុទ្ធសាស្ត្រទីផ្សារ និងស្វែងរកការឧបត្ថម្ភគាំទ្រពីវិស័យឯកជន រៀបចំផែនការលក់ឈ្មោះ Phnom Penh SEA Games ឆ្នាំ ២០២៣ ឡូហ្គូរូបតំណាង និងរៀបចំផែនការលក់សំបុត្រ ។

**២.២.១២. គណៈកម្មការពិធីការ**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំផែនការបដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិ រៀបចំផែនការកម្មវិធីបំពាក់មេដាយគ្រប់ប្រភេទកីឡា និងវិញ្ញាសាក្នុងពេលប្រកួត ពិធីការភ្ញៀវក្នុងពិធីបើក បិទការប្រកួតជាផ្លូវការ ។

**២.២.១៣. គណៈកម្មការពិធីបើក និងបិទ**

គណៈកម្មការនេះមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំកម្មវិធីបើក និងបិទ រៀបចំកម្មវិធី និងសេណារីយ៉ូ ផ្ទាំងទស្សនីយភាពសំខាន់ៗពាក់ព័ន្ធការសម្តែងទ្រង់ទ្រាយធំ និងស្វែងរកកិច្ចសហការជាមួយដៃគូក្រុមហ៊ុនឯកជនមានបទពិសោធន៍ និងស្នាដៃរៀបចំហ្គេមធំៗចូលរួម ។

**២.២.១៤. លេខាធិការដ្ឋាន**

លេខាធិការដ្ឋានមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំកិច្ចការរដ្ឋបាល គ.ជ.ប.អ. ឱ្យមានប្រសិទ្ធភាព ធ្វើជាសេនាធិការ និងគ្រប់គ្រងកិច្ចការរដ្ឋបាល គ.ជ.ប.អ. គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ និងធ្វើជាច្រកចេញចូលតែមួយគត់នូវលិខិតបទដ្ឋាន បទប្បញ្ញត្តិ លិខិតរដ្ឋបាល សេចក្តីថ្លែងការណ៍ និងសេចក្តីប្រកាសរបស់ គ.ជ.ប.អ. ។

ទន្ទឹមនឹងតួនាទី និងភារកិច្ចដែលមានជាអាទិ៍ខាងលើនេះ គណៈកម្មការទាំង ១៤ មានភារកិច្ចរៀបចំរបាយការណ៍សកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងបំពេញការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន គ.ជ.ប.អ. ។


រចនាសម្ព័ន្ធគ្រប់គ្រងគណៈកម្មាធិការជាតិរៀបចំSEA Games លើកទី៣២ ឆ្នាំ២០២៣ (CAMSOC)
ប្រធាន
ក្រសួង ស្ថាប័នពាក់ព័ន្ធ អនុប្រធាន
អនុប្រធានអចិន្ត្រៃយ៍
អាជ្ញាធរ រាជធានី-ខេត្ត អនុប្រធាន
អគ្គលេខាធិការដ្ឋាន
លេខាធិការដ្ឋាន
គណៈកម្មការ ហិរញ្ញវត្ថុ និងផ្គត់ផ្គង់
គណៈកម្មការ សន្តិសុខ-សណ្តាប់ធ្នាប់
គណៈកម្មការ ស្នាក់នៅ-ហូបចុក-ដឹកជញ្ជូន
គណៈកម្មការ អ្នកស្ម័គ្រចិត្ត
គណៈកម្មការ ពិធីការ បដិសណ្ឋារកិច្ច
គណៈកម្មការ ពិធីបើក-បិទ

៥

## ផ្នែកទី ៣ ប្រភពថវិកានិងធនធាន និងមុខសញ្ញាចំណាយ

### ៣.១. ប្រភពថវិកា និងធនធាន

ថវិកា សំដៅដល់ចំណូល-ចំណាយជាសាច់ប្រាក់សម្រាប់ប្រើប្រាស់បម្រើឱ្យការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប.អ.។ ចំណែកឯធនធាន សំដៅដល់សម្ភារ ឧបករណ៍ និងមធ្យោបាយនានា ដែលបម្រើឱ្យការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប.អ.។

ជាគោលការណ៍ ថវិកា និងធនធានទាំងអស់ត្រូវគ្រប់គ្រងប្រកបដោយសមាហរណកម្ម និងអនុវត្តក្នុងលក្ខណៈបំពេញឱ្យគ្នានៅក្រោមប្រព័ន្ធដឹកនាំនិងគ្រប់គ្រងរួម នៃ គ.ជ.ប.អ.។

ប្រភពថវិកា និងធនធានសម្រាប់ គ.ជ.ប.អ. រួមមាន ៖

#### ៣.១.១. ថវិការដ្ឋ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ ២០២៣ តាមរយៈអនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៨ ដោយបានអនុញ្ញាតឱ្យគ្រោងកញ្ចប់ថវិកាវិភាគទានរបស់រាជរដ្ឋាភិបាលប្រចាំឆ្នាំសម្រាប់ការរៀបចំព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ឆ្នាំ ២០២៣ ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានត្រៀមបម្រុងកញ្ចប់ថវិកាចំនួន ៣០ ប៊ីលានរៀល ជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០១៨ មក ។ សម្រាប់ឆ្នាំ២០២២-២០២៣ រាជរដ្ឋាភិបាលបានគ្រោងផែនការថវិកាជូន គ.ជ.ប.អ. សម្រាប់ការដំណើរការរៀបចំមុនពេល ក្នុងអំឡុងពេល និងក្រោយពេលព្រឹត្តិការណ៍នេះ ចំនួនប្រមាណ ៥០៥ ប៊ីលានរៀលបន្ថែមទៀត ។

#### ៣.១.២. ប្រភពផ្សេងទៀត

ប្រភពថវិកាក្រៅពីប្រភពថវិការដ្ឋ រួមមានចំណូលដែលបានមកពីការរៀបចំព្រឹត្តិការណ៍ ដូចជាការផ្សាយពាណិជ្ជកម្ម, មជ្ឈមណ្ឌលសារព័ត៌មាន, សកម្មភាពរត់ និងជិះ, សប្បុរសជន, អាជ្ញាប័ណ្ណ និងការលក់ដូរ, ថ្លៃចូលរួមប្រកួតរបស់អត្តពលិក, ការលក់សំបុត្រ, ចំណត និងការផ្តល់អាជ្ញាប័ណ្ណភ្នាល់កីឡា និងចំណូលពីសប្បុរសជន ។ល។ ទោះជាយ៉ាងនេះក្តី ចំណូលដែលបានមកពីប្រភពនេះ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ពោលគឺរហូតទាល់តែកៀកពេលរៀបចំព្រឹត្តិការណ៍ទើបអាចព្យាករណ៍បានកាន់តែសុក្រឹត។ ចំណែកឯមុខចំណូលមួយចំនួនទៀត តម្រូវឱ្យមានការពិភាក្សាគ្នាបន្ថែមទៀតរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអបរំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធ ដូចជាចំណូលដែលបានមកពីការផ្តល់អាជ្ញាប័ណ្ណភ្នាល់កីឡាជាដើម ។

### ៣.២. មុខសញ្ញាចំណាយ

មុខសញ្ញាចំណាយរបស់មូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ត្រូវបានកំណត់ក្នុងប្រភេទចំណាយប្រចាំ និងចំណាយមិនប្រចាំ ដូចខាងក្រោម ៖

**I. ចំណាយប្រចាំ**

**ក. ចំណាយលើបុគ្គលិក និងការឧបត្ថម្ភ**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ការឧបត្ថម្ភក្រុមជំនួយការ ពិធីការថ្នាក់ដឹកនាំ គ.ជ.ប.អ. មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប.អ. មន្ត្រីបម្រើប្រតិបត្តិការស៊ីហ្គេម, ចំណាយបង់សេវាធានារ៉ាប់រងសម្រាប់អត្តពលិកកីឡាករប្រកួត, ប្រាក់ឧបត្ថម្ភសម្រាប់បម្រើឱ្យគណៈកម្មការជំនាញ និងចំណាយផ្សេងៗ ។

**ខ. ចំណាយសោហ៊ុយបេសកកម្មនៅក្នុង និងក្រៅប្រទេស**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយចុះត្រួតពិនិត្យទីលានប្រកួត និងចំណាយចូលរួមរួមសិក្ខាសាលា ឬទស្សនកិច្ចសិក្សានៅក្រៅប្រទេស ។

ចំណាយបេសកកម្មនៅក្នុងនិងក្រៅប្រទេស ត្រូវអនុវត្តតាមគោលរបប និងវិធាននិងនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១ ស្ដីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ, ប្រកាសលេខ ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១ ស្ដីពីវិធាននិងនីតិវិធីអនុវត្តចំណាយប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ លិខិតលេខ ២៨៧ សហវ.ហក ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១៥ ស្ដីពីគោលការណ៍អនុញ្ញាតផ្ដល់ប្រាក់ឧបត្ថម្ភជូនបុគ្គលិកសហព័ន្ធកីឡា គ្រូបង្វឹក គ្រូជំនួយ អាជ្ញាកណ្ដាល ចៅក្រម និងកីឡាករគ្រប់ប្រភេទ រួមទាំងសិស្ស និស្សិត យុវជន បុគ្គលិកក្រុមហ៊ុន គ្រូមិនមែនក្របខ័ណ្ឌរដ្ឋ និងប្រជាពលរដ្ឋ និងលិខិតលេខ៣០៦ សហវ.អថ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ២០២២ ស្ដីពីការបន្តសុពលភាពលិខិតលេខ ២៨៧ សហវ.ហក. ។

**គ. ចំណាយរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្ដុះបណ្ដាល**

មុខសញ្ញាចំណាយនេះរួមមាន ចំណាយរៀបចំកិច្ចប្រជុំរបស់ គ.ជ.ប.អ. សិក្ខាសាលា និងការបណ្ដុះបណ្ដាលនានារបស់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ។

ចំណាយរៀបចំការបណ្ដុះបណ្ដាល សិក្ខាសាលា និងការរៀបចំព្រឹត្តិការណ៍នានា ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ១០២ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២១ ស្ដីពីវិធាននិងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្ដុះបណ្ដាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទ សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។ ចំពោះមុខសញ្ញាចំណាយដែលមិនបានចែង ឬទំហំទឹកប្រាក់ចំណាយលើសពីការកំណត់ក្នុងប្រកាសនេះ ត្រូវស្នើសុំគោលការណ៍អនុញ្ញាតជាមុនពីប្រធាន គ.ជ.ប.អ. ឬអ្នកដែលទទួលបានការប្រគល់សិទ្ធិ ។ ដោយឡែក ក្នុងករណីទឹកប្រាក់ចំណាយមានទំហំធំ និងមានវេទយិតភាពខ្ពស់ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ។

ចំពោះការរៀបចំសន្និសីទ សិក្ខាសាលា និងប្រជុំអន្តរជាតិរបស់សហព័ន្ធកីឡាអន្តរជាតិ សហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ " SEAGF Council " និងថ្នាក់នាយបេសកម្ម ( CDM-Seminar ) ត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ពីប្រធាន គ.ជ.ប.អ. ឬអ្នកដែលទទួលបានការប្រគល់សិទ្ធិ ។ ចំពោះការអនុវត្តចំណាយ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងក្នុងជ្យាក្រាម ២.១. ឬ ២.២. នៃគោលការណ៍ណែនាំនេះ ។

**ឃ. ចំណាយជួលអ្នកជំនាញការ និងគ្រូបង្វឹកបរទេស**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយលើការជួល និងថ្លៃសំបុត្រយន្តហោះ និងចំណាយពាក់ព័ន្ធនឹងអ្នកជំនាញ និងគ្រូបង្វឹកបរទេស ។

ចំណាយលើការជួលជំនាញការបរទេសត្រូវវាយតម្លៃគុណវុឌ្ឍិ សមត្ថភាព បទពិសោធន៍ និងជ្រើសរើស ដោយគណៈកម្មការកីឡា និងបទប្បញ្ញត្តិ ។ រីឯការចរចាតម្លៃ និងកំណត់តម្លៃត្រូវកំណត់ដោយអគ្គលេខាធិការបន្ទាប់ពីមានការចូលរួមពីប្រធានគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ និងមានការឯកភាពជាគោលការណ៍ពីថ្នាក់ដឹកនាំ គ.ជ.ប.អ. ។

ចំណាយលើការជួលគ្រូបង្វឹកកីឡា ត្រូវគោរពតាមនិយាមបច្ចេកទេសកីឡា និងមានតែសហព័ន្ធកីឡាជាតិប៉ុណ្ណោះដែលមានសិទ្ធិវាយតម្លៃកម្រិតសមត្ថភាព គុណផលកីឡា ដើម្បីជ្រើសរើសគ្រូបង្វឹកបរទេស ។ ទន្ទឹមនឹងនេះ ការចរចាតម្លៃ និងកំណត់តម្លៃត្រូវកំណត់ដោយអគ្គលេខាធិការ ដោយមានការចូលរួមផ្តល់យោបល់ពីប្រធានគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ និងមានការឯកភាពជាគោលការណ៍របស់ថ្នាក់ដឹកនាំ គ.ជ.ប.អ. ។

**ង. ចំណាយការងារអភិវឌ្ឍន៍បច្ចេកទេសកីឡា**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយបញ្ជូនអត្តពលិកទៅចូលរួមការបណ្តុះបណ្តាលនៅក្រៅប្រទេស, ការបញ្ជូនអត្តពលិក គ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម ទៅចូលរួមប្រកួតអន្តរជាតិ និងចំណាយផ្គត់ផ្គង់អាហារបំប៉នអត្តពលិកមុនពេលប្រកួត ។

គោលការណ៍លើការអភិវឌ្ឍជំនាញបច្ចេកទេសកីឡារបស់ក្រុមជម្រើសជាតិ និងសហព័ន្ធកីឡាជាតិ ត្រូវមានការអនុញ្ញាតពីប្រធាន គ.ជ.ប.អ. តាមរយៈអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.អ. ។រីឯការអនុវត្តចំណាយត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងដ្យាក្រាម ២.១. ឬ ២.២. នៃគោលការណ៍ណែនាំនេះ ។

ការអនុវត្តចំណាយក្នុងការបញ្ជូនអត្តពលិកទៅហ្វឹកហាត់ ឬទៅប្រកួតនៅបរទេស ត្រូវទូទាត់តាមវិក្កយបត្រជាក់ស្តែងរបស់ម្ចាស់ប្រទេសដែលទទួលយកអត្តពលិក ។ ទន្ទឹមនឹងនេះ មុខចំណាយណាដែលទទួលរ៉ាប់រងដោយភាគីម្ចាស់ផ្ទះ នោះនឹងមិនមានការឧបត្ថម្ភបន្ថែមទេ លើកលែងតែប្រាក់ហោប៉ៅ ។ ដោយឡែក ក្នុងករណីមិនមានវិក្កយបត្រ ឬមិនមានការរ៉ាប់រងចំណាយពីប្រទេសម្ចាស់ផ្ទះ នោះការឧបត្ថម្ភលើការហូបចុក ស្នាក់នៅ និងចំណាយពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមគោលការណ៍ស្តង់ដាកម្រិតមធ្យម ។ ស្តង់ដាកម្រិតមធ្យមនៅទីនេះ សំដៅដល់កម្រិតឧបត្ថម្ភស្នាក់នៅ និងហូបចុក ត្រឹមសណ្ឋាគារផ្កាយបី ដល់ផ្កាយបួន ។

**ច. ចំណាយទទួលភ្ញៀវជាតិ និងអន្តរជាតិ**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយសម្រាប់ទទួលភ្ញៀវអន្តរជាតិដែលមកទស្សនាការប្រកួតកីឡា និងព្រឹត្តិការណ៍នានា, ចំណាយលើអាហារ និងការស្នាក់នៅរបស់ប្រតិភូកីឡា និងមន្ត្រីបច្ចេកទេសកីឡាអន្តរជាតិ, ចំណាយសម្រាប់អាហារ ភេសជ្ជៈ និងស្នាក់នៅរបស់កងកម្លាំង អ្នកស្ម័គ្រចិត្ត និងការសម្តែងសិល្បៈទទួលភ្ញៀវនៅអាកាសយានដ្ឋាន និងតាមទីកន្លែងប្រកួតនានា ។ល។ ចំណាយសម្រាប់ស្នាក់នៅជូនប្រធានប្រតិភូ ឬសមាជិកប្រតិភូ និងមន្ត្រីបច្ចេកទេសកីឡាអន្តរជាតិត្រូវអនុវត្តតាមគោលការណ៍បដិការ និងឈរលើគោលការណ៍សន្សំសំចៃ និងតាមលទ្ធភាពថវិកា ។

**ឆ. ចំណាយផ្សព្វផ្សាយ និងព័ត៌មានវិទ្យា**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ការផលិតស្ប៉តខ្លីៗ, ការផ្សព្វផ្សាយតាមបណ្តាញសង្គម, ការបោះពុម្ពខិត្តប័ណ្ណ ការរៀបចំដំឡើងប្រព័ន្ធ Game Information System និងរៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ IBC និងមជ្ឈមណ្ឌលព័ត៌មានសំខាន់ៗ ។ល។

**ជ. ចំណាយរៀបចំព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិ**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយរៀបចំព្រឹត្តិការណ៍ជាតិដូចជាផ្សព្វផ្សាយពីយុទ្ធនាការអប់រំសង្គមស្តីពីប្រជាជនម្នាក់លេងកីឡាមួយមុខ, និងការរៀបចំព្រឹត្តិការណ៍អន្តរជាតិ និងចំណាយពាក់ព័ន្ធ ដូចជា ការជួលទីលានប្រកួត, សម្ភារ បរិក្ខារសម្រាប់បម្រើឱ្យការប្រកួត, សម្ភារនិងបរិក្ខារពេទ្យសម្រាប់គ្លីនិកចល័ត, ការរៀបចំ និងផ្សេងៗពាក់

ទស្សនីយភាពសម្តែងបើក-បិទ សម្រាប់ស៊ីហ្គេម និងអាស៊ានប៉ារ៉ាហ្គេម និងចំណាយជួលសម្ភារ បរិក្ខារសម្រាប់ការប្រកួតអាស៊ានប៉ារ៉ាហ្គេម ។ល។

**ឈ. ចំណាយលើមធ្យោបាយដឹកជញ្ជូន**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយទិញប្រេងឥន្ធនៈ, ចំណាយទិញសំបុត្រយន្តហោះជូនប្រតិភូ និងមន្ត្រីបច្ចេកទេសកីឡាអន្តរជាតិ, ការដឹកជញ្ជូនឧបករណ៍ បរិក្ខារ សម្ភារកីឡា នៅក្នុងស្រុក, ការដឹកជញ្ជូនប្រតិភូកីឡា ប្រតិភូកីឡា អត្តពលិក អ្នកស្ម័គ្រចិត្ត, ចំណាយធ្វើដំណើរ ស្នាក់នៅ ហូបចុក ធ្វើដំណើររបស់ប្រតិភូកីឡាទាំង ១០ ប្រទេស និង ចំណាយធ្វើដំណើរ ហូបចុក ស្នាក់នៅសម្រាប់រៀបចំរត់ភ្លើងគប់ទាំង ៥ ខេត្ត ។

**ញ. ចំណាយសម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយលើសម្ភារការិយាល័យ, សម្ភារបោះពុម្ព, ភេសជ្ជៈសម្រាប់ថ្នាក់ដឹកនាំ និងទទួលភ្ញៀវ, សម្ភារអនាម័យ និងចំណាយផ្សេងៗ ។

**ដ. ចំណាយទិញឯកសណ្ឋាន**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ឯកសណ្ឋានប្រតិភូកីឡា និងអត្តពលិក, ឯកសណ្ឋានគណៈកម្មការជំនាញ និងចំណាយពាក់ព័ន្ធផ្សេងទៀត ។

**ឋ. ចំណាយទិញឧបករណ៍ និងសម្ភារបច្ចេកទេសកីឡាស្តង់ដា**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ចំណាយលើឧបករណ៍ និងសម្ភារសម្រាប់កីឡា ដូចជា សម្លៀកបំពាក់កីឡា, បាល់, ប៊ូល, សម្ភារការពាររាងកាយ, កង់ប្រណាំង, ស្បែកជើងកីឡា និងឧបករណ៍ និងសម្ភារបច្ចេកទេសសម្រាប់គណៈកម្មការជំនាញ ។ល។

ចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ត្រូវអនុវត្តតាមនីតិវិធីរួមសម្រាប់ការគ្រប់គ្រងកិច្ចលទ្ធកម្មគម្រោង (Standard Operating Procedure on Procurement) ដូចការគ្រប់គ្រងកិច្ចលទ្ធកម្មនៃការគ្រប់គ្រងថវិកានិងធនធានសម្រាប់ប្រយុទ្ធនឹងជំងឺកូវីដ-១៩។

**ឌ. ចំណាយបរិក្ខារនិងគ្រឿងសង្ហារិម**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន កុំព្យូទ័រ, ព្រីនធ័រ, តុកៅអីការិយាល័យ, ទូដាក់ឯកសារ, បរិក្ខារបច្ចេកទេសបម្រើឱ្យគណៈកម្មការជំនាញ និងបរិក្ខារផ្សេងៗទៀត ។

**ឍ. ចំណាយជួសជុល និងថែទាំ**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមាន ការជួសជុលបរិក្ខារ អគារ និងហេដ្ឋារចនាសម្ពន្ធកីឡានានា ។

**ណ. ចំណាយមិនបានគ្រោងទុក**

មុខសញ្ញាចំណាយនេះជាអាទិ៍រួមមានចំណាយទាំងឡាយណាដែលអាចកើតមានឡើងជាយថាហេតុ និងមិនអាចព្យាករទុកជាមុនបាន ។

មុខសញ្ញាចំណាយនេះត្រូវបានអនុញ្ញាតឱ្យអនុវត្តចំណាយក្នុងរង្វង់មិនលើសពី ៣% នៃផែនការថវិកាឆ្នាំ២០២២-២០២៣ ដែលរាជរដ្ឋាភិបាលបានអនុម័ត ដោយត្រូវស្នើសុំការឯកភាពជាមុន ពីប្រធាន គ.ជ.ប.អ មុននឹងអនុវត្តចំណាយ ។ ក្នុងករណីមានតម្រូវការលើសពីនេះ ត្រូវស្នើសុំការពិនិត្យនិងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

II. **ចំណាយមិនប្រចាំ**

ចំណាយមិនប្រចាំមានជាអាទិ៍៖

- ការរៀបចំ សាងសង់អគារ ទីលានប្រកួត និងហេដ្ឋារចនាសម្ព័ន្ធកីឡា
- ការទិញសម្ភារ ឧបករណ៍បរិក្ខារកីឡាធំៗ សម្រាប់បំពាក់នៅតាមទីលានប្រកួត សម្រាប់ហ្វឹកហាត់ ឬសម្រាប់អង្គភាពប្រតិបត្តិ
- ការទិញមធ្យោបាយដឹកជញ្ជូន
- ការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

មុខសញ្ញាចំណាយ និងគោលការណ៍នៅក្នុងចំណុច ៣.២ នេះ ទាំងចំណាយប្រចាំ និងទាំងចំណាយមិនប្រចាំ គឺជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជាប្រចាំ តាមភាពចាំបាច់ និងតាមការសម្រេចរបស់ប្រធាន គ.ជ.ប.អ. តាមសំណើរបស់ប្រធានគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ អគ្គលេខាធិការ និងអនុប្រធានអចិន្ត្រៃយ៍ ។

**ផ្នែកទី ៤ យន្តការនៃការទទួលខុសត្រូវលើការគ្រប់គ្រងថវិកា និងធនធានរបស់ គ.ជ.ប.អ.**

ជាគោលការណ៍ ក្នុងក្របខ័ណ្ឌនៃថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា គឺជាអាណាប័កដើមខ្សែនៃថវិកា ។ ដូច្នេះ ថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ត្រូវផ្ទេរពីឥណទានមិនទាន់បែងចែកទៅក្នុងកញ្ចប់ឥណទានថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ចំណែកឯក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅតែជាស្ថាប័នទទួលខុសត្រូវលើការត្រួតពិនិត្យហិរញ្ញវត្ថុ និងមានសិទ្ធិសម្រេច ឬស្នើសុំរាជរដ្ឋាភិបាលសម្រេចផ្តល់ថវិកា ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន យុវជន និងកីឡា ត្រូវស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបោះផ្សាយអាណត្តិបើកប្រាក់ ដោយផ្ទេរចូលគណនីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ។ គ.ជ.ប.អ. ត្រូវស្នើសុំទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីទម្លាក់សាច់ប្រាក់ទៅក្នុងគណនីរបស់ គ.ជ.ប.អ. សម្រាប់ដំណើរការប្រតិបត្តិការណ៍តាមផែនការសកម្មភាពដែលបានគ្រោងទុក ។

យោងប្រកាសលេខ ៧២៦ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០១៩ ស្តីពីវិធាននិងនីតិវិធីចំណាយមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ ២០២៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់សិទ្ធិស្វ័យសម្រេច និងការទទួលខុសត្រូវពេញលេញលើការអនុវត្តចំណាយជូន គ.ជ.ប.អ. ដែលបានទទួលមូលនិធិពីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ ២០២៣ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។

ដោយផ្អែកលើរចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ជ.ប.អ. យន្តការទទួលខុសត្រូវលើការគ្រប់គ្រងថវិកានិងធនធានសម្ភារ ឧបករណ៍ និងមធ្យោបាយគ្រប់ប្រភេទ និងគ្រប់ប្រភព ក្នុងក្របខ័ណ្ឌនៃដែនសមត្ថកិច្ចរបស់ គ.ជ.ប.អ. ត្រូវបានកំណត់ដូចខាងក្រោម ៖

**៤.១. គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ (គ.ជ.ប.អ.)**

គ.ជ.ប.អ. មានតួនាទីនិងភារកិច្ច ព្រមទាំងកិច្ចដំណើរការដូចមានចែងក្នុងមាត្រា៣, មាត្រា ៥ ៦ ៧ នៃអនុក្រឹត្យលេខ២២៣ អនក្រ.បក. ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំ

ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ។ គ.ជ.ប.អ. ជាយន្តការដឹកនាំ គ្រប់គ្រង និងរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ដែលកម្ពុជារៀបចំជាម្ចាស់ផ្ទះ និងជាយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការមេ និងផែនការសកម្មភាពតាមដំណាក់កាលរបស់គណៈកម្មការជំនាញនីមួយៗ ។

**៤.១.១. ប្រធានគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣**

ប្រធាន គ.ជ.ប.អ. គឺជាអាណាប័កផ្ទេរសិទ្ធិពេញលេញនៃថវិកា គ.ជ.ប.អ. ដែលមានសិទ្ធិអំណាចក្នុងការបញ្ជាចំណូល-ចំណាយថវិការបស់ គ.ជ.ប.អ. ស្របតាមបទដ្ឋានគតិយុត្តជាធរមាន ។ ប្រធាន គ.ជ.ប.អ. អាចផ្ទេរសិទ្ធិបន្តជូនតំណាង តាមការចាំបាច់ក្នុងនាមជាអាណាប័កជំនួស ពាក់ព័ន្ធនឹងសមត្ថកិច្ចដែលខ្លួនទទួលបន្ទុក ក្នុងក្របខ័ណ្ឌនៃ គ.ជ.ប.អ. ។

**៤.១.២. អគ្គលេខាធិការនៃ គ.ជ.ប.អ.**

អគ្គលេខាធិការនៃ គ.ជ.ប.អ. មានតួនាទីដឹកនាំការងាររួមរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មការជំនាញ លេខាធិការដ្ឋាន និងទទួលបន្ទុកជាសេនាធិការផ្ទាល់ជូនអនុប្រធានអចិន្ត្រៃយ៍ និងប្រធាន គ.ជ.ប.អ. ក្នុងការសម្រប-សម្រួល ទំនាក់ទំនង និងដឹកនាំចាត់ចែងរាល់សកម្មភាពរបស់គណៈកម្មការជំនាញនានា និងលេខាធិការដ្ឋានចំណុះ គ.ជ.ប.អ.។

អគ្គលេខាធិការនៃ គ.ជ.ប.អ. មានអគ្គលេខាធិការរងមួយចំនួន ដែលមានតួនាទីនិងភារកិច្ចតាមជំនាញរៀងៗខ្លួន រួមមាន ជំនួយការផ្នែករដ្ឋបាលទូទៅ, ផ្នែកផែនការ និងហិរញ្ញវត្ថុ និង ផ្នែកជំនាញ និងបច្ចេកទេសកីឡា ។

**៤.១.៣. លេខាធិការដ្ឋាននៃ គ.ជ.ប.អ.**

លេខាធិការដ្ឋានមានតួនាទី និងភារកិច្ចជាអាទិ៍ រៀបចំកិច្ចការរដ្ឋបាល គ.ជ.ប.អ. ឱ្យមានប្រសិទ្ធភាព ធ្វើជាសេនាធិការ និងគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់ គ.ជ.ប.អ. និងគណៈកម្មការជំនាញ និងធ្វើជាច្រកចេញចូលតែមួយគត់នូវលិខិតបទដ្ឋាន បទប្បញ្ញត្តិ លិខិតរដ្ឋបាល សេចក្ដីថ្លែងការណ៍ និងសេចក្ដីប្រកាសរបស់ គ.ជ.ប.អ. ។

**៤.២. គណៈកម្មការជំនាញចំណុះ គ.ជ.ប.អ.**

យោងតាមអនុក្រឹត្យលេខ ២២៣ អនក្រ.បក. ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ និងអនុក្រឹត្យលេខ ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្ដីពីការកែសម្រួលមាត្រា២ និងមាត្រា៧ នៃអនុក្រឹត្យលេខ ២២៣ អនក្រ.បក. ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣, គ.ជ.ប.អ. មានគណៈកម្មការជំនាញសរុបចំនួន ១៣ និងលេខាធិការដ្ឋានចំនួន ១ ក្រោមចំណុះ ជាសេនាធិការផ្នែកបច្ចេកទេស និងប្រតិបត្តិការ ដោយក្នុងនោះ លើទិដ្ឋភាពគ្រប់គ្រងថវិកា និងធនធាន ត្រូវបានបែងចែកជា ÷ លេខាធិការដ្ឋាន និងគណៈកម្មការជំនាញ (មិនមែនគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់) ចំនួន ១៣ និងគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ។

**៤.២.១. គណៈកម្មការជំនាញ និងលេខាធិការដ្ឋាន**

ជារួម លើទិដ្ឋភាពថវិកា, គណៈកម្មការជំនាញទាំង ១៣ និងលេខាធិការដ្ឋាន អាចមានមុខងារពីរ (២) មុខងារ ជាអ្នកត្រួតពិនិត្យ និងសម្របសម្រួលលើការអនុវត្តថវិកានិងប្រើប្រាស់ធនធាន គ.ជ.ប.អ. របស់អង្គភាពប្រតិបត្តិរបស់ខ្លួន

នានា និង (២) មុខងារជាអង្គភាពប្រតិបត្តិដែលអនុវត្តថវិកាដោយខ្លួនឯង និងអាចជាអាណាប័កជំនួស ពាក់ព័ន្ធនឹងសមត្ថកិច្ចដែលខ្លួនទទួលបន្ទុក សម្រាប់កិច្ចប្រតិបត្តិការចំណូល-ចំណាយរបស់ គ.ជ.ប.អ. ។

**៤.២.២. គណៈកម្មការផ្គត់ផ្គង់និងហិរញ្ញវត្ថុ (គ.ហ.ផ.)**

គណៈកម្មការផ្គត់ផ្គង់ និងហិរញ្ញវត្ថុនៃ គ.ជ.ប.អ. មានតួនាទីជាអ្នករៀបចំគម្រោងផែនការហិរញ្ញវត្ថុ គ្រប់គ្រងសាច់ប្រាក់ចំណូល-ចំណាយ និងគ្រប់គ្រងទ្រព្យសម្បត្តិ និងបញ្ជីសារពើភណ្ឌគ្រប់ប្រភេទរបស់ គ.ជ.ប.អ. ។ ទន្ទឹមនឹងនេះ គណៈកម្មការនេះ មានភារកិច្ចត្រូវរៀបចំគោលការណ៍និងនីតិវិធីអនុវត្តថវិកាស្របតាមនីតិវិធីហិរញ្ញវត្ថុ ។

គណៈកម្មការផ្គត់ផ្គង់និងហិរញ្ញវត្ថុ មានរចនាសម្ព័ន្ធក្រោមចំណុះចំនួន ៨ គឺ (១) លេខាធិការដ្ឋាននៃ គ.ហ.ផ., (២) ផ្នែកបេឡា, (៣) ផ្នែកគណនេយ្យ, (៤) ផ្នែកសវនកម្ម, (៥) ផ្នែកផែនការហិរញ្ញវត្ថុ, (៦) ផ្នែកផ្គត់ផ្គង់, (៧) ក្រុមជំនួយការ និង (៨) ក្រុមការងារបច្ចេកទេសលិខិតបទដ្ឋានគតិយុត្ត ។ សមាសភាពគណៈកម្មការផ្គត់ផ្គង់និងហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយប្រមូលផ្តុំសមាសភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងការពារជាតិ, អាជ្ញាធរសវនកម្មជាតិ និងគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ដែលជាយន្តការតែមួយក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនទៅនឹងកន្លែង និងជាប្រព័ន្ធការងារគាំទ្រ សម្រាប់ឆ្លើយតបទៅនឹងការអនុវត្តថវិការបស់ គ.ជ.ប.អ. ដែលតម្រូវឱ្យមានភាពបត់បែន និងមានការប្រែប្រួលឆាប់រហ័ស ប៉ុន្តែរក្សាបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ។

គណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់មានរចនាសម្ព័ន្ធ ដូចខាងក្រោម ÷






## ៤.៣. គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា, មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា និងសហព័ន្ធកីឡាជាតិ

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាគឺជាអង្គភាពប្រតិបត្តិមួយនៃមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ។ ទោះជាយ៉ាងនេះក្តី ក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់ថវិកានេះ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា មានមុខសញ្ញាចំណាយមួយចំនួនតូចតែប៉ុណ្ណោះដែលពាក់ព័ន្ធនឹងចំណាយដំណើរការសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន ។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា ដែលជាអង្គភាពប្រតិបត្តិដែរនោះ មានមុខសញ្ញាចំណាយមួយចំនួនដែលពាក់ព័ន្ធនឹងការឧបត្ថម្ភអត្តពលិកក្នុងការប្រមូលផ្តុំហ្វឹកហ្វឺន ប្រាក់រង្វាន់ជ័យលាភីអត្តពលិក និងចំណាយពាក់ព័ន្ធមួយចំនួនទៀត ក្នុងក្របខ័ណ្ឌក្រសួងអប់រំ យុវជន និងកីឡា ។ ដោយឡែក គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងសហព័ន្ធកីឡាជាតិ ក៏ជាអង្គភាពប្រតិបត្តិនៃថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ដែលត្រូវទទួលខុសត្រូវលើការប្រើប្រាស់ថវិកា និងធនធានជាសម្ភារ ឧបករណ៍និងមធ្យោបាយនានា សម្រាប់បម្រើឱ្យសកម្មភាពការងាររៀបចំការប្រកួត និងសកម្មភាពចាំបាច់មួយចំនួនទៀត រួមមានការបណ្តុះបណ្តាល ហ្វឹកហ្វឺនអត្តពលិកឱ្យមានប្រសិទ្ធផលកីឡាកម្រិតខ្ពស់ បណ្តុះបណ្តាលអាជ្ញាកណ្តាល ចៅក្រម ។ល។ ក្នុងករណីមានតម្រូវការស្នើសុំការគាំទ្រ និងជំនួយឧបត្ថម្ភពី គ.ជ.ប.អ. ទាំងផ្នែកថវិកា ឧបករណ៍ និងសម្ភារ, គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា និងសហព័ន្ធកីឡាជាតិ ត្រូវសម្របសម្រួលជាមួយគណៈកម្មការកីឡា និងបទប្បញ្ញត្តិ ក្នុងការលើកសំណើ និងផ្តល់របាយការណ៍អនុវត្ត ។

ប្រតិបត្តិករនៃថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ មានបង្ហាញនៅក្នុងរចនាសម្ពន្ធដូចខាងក្រោម ÷

## រចនាសម្ព័ន្ធការប្រើប្រាស់ថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣

**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**
**និងជាប្រធានគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី ៣២ ឆ្នាំ២០២៣**

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.អ.**

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.អ.**

**សហព័ន្ធកីឡាជាតិ**

1. សហព័ន្ធខ្មែរអត្តពលកម្មស្ម័គ្រចិត្ត
2. សហព័ន្ធខ្មែរកីឡាហែលទឹក
3. សហព័ន្ធកីឡាវាយសីកម្ពុជា
4. សហព័ន្ធកីឡាបាល់បោះកម្ពុជា
5. សហព័ន្ធកីឡាប្រដាល់សកលកម្ពុជា
6. សហព័ន្ធកីឡាប្រដាល់គុនខ្មែរ
7. សហព័ន្ធកីឡាបាល់ទាត់កម្ពុជា
8. សហព័ន្ធកីឡាចំបាប់កម្ពុជា
9. សហព័ន្ធកីឡាវាយកូនឈ្លីលើតុកម្ពុជា
10. ខេមរសហព័ន្ធតេក្វាន់ដូ WT
11. សហព័ន្ធកីឡាតេក្វាន់ដូ ITFកម្ពុជា
12. សហព័ន្ធកីឡាវាយកូនបាល់កម្ពុជា
13. សហព័ន្ធកីឡាបាល់ទះកម្ពុជា
14. សហព័ន្ធកីឡាប៊ូល និងប៉េងតងកម្ពុជា
15. សហព័ន្ធកីឡាល្បុក្កតោកម្ពុជា
16. សហព័ន្ធកីឡាកាយសម្ព័ន្ធកម្ពុជា
17. សហព័ន្ធវ៉ូវីណាមកម្ពុជា
18. ខេមរៈសហព័ន្ធយូដូ
19. សហព័ន្ធការ៉ាតេកម្ពុជា
20. សហព័ន្ធស៊ូរិនហ្សិកាំប៉ូកម្ពុជា
21. សហព័ន្ធខ្មែរកីឡាទោចក្រយាន
22. សហព័ន្ធកីឡាទ្រីយ៉ាត្លុងកម្ពុជា
23. សហព័ន្ធកីឡាបាញ់កាំភ្លើងកម្ពុជា
24. សហព័ន្ធកីឡាសីដក់ និងឈិនឡូន
25. សហព័ន្ធកីឡាស្នូហ្គឺតនិងប៊ីយ៉ាកម្ពុជា
26. សហព័ន្ធកីឡាអុកចត្រង្គកម្ពុជា
27. សហព័ន្ធកម្ពុជាបង្ហាត់ជិះសេះ
28. សហព័ន្ធកីឡាម៉ូតូទឹកកម្ពុជា
29. សហព័ន្ធកីឡាវូស៊ូកម្ពុជា
30. សហព័ន្ធកីឡាហុកគីកម្ពុជា
31. សហព័ន្ធកីឡារាំកម្ពុជា
32. សហព័ន្ធកីឡាឃីកបុកស៊ីងកម្ពុជា
33. សហព័ន្ធកីឡាកាយវប្បកម្មនិងលំហាត់ប្រាណកម្ពុជា
34. សហព័ន្ធកីឡាគុនដាវកម្ពុជា
35. សហព័ន្ធកីឡាជីជីតស៊ូកម្ពុជា
36. សហព័ន្ធកីឡាទូកកានូ និងរ៉ូអ៊ីងកម្ពុជា
37. សហព័ន្ធកីឡាវាយកូនគោលកម្ពុជា
38. សហព័ន្ធកីឡាទូកក្ដោងកម្ពុជា
39. សហព័ន្ធកីឡាលើកទម្ងន់កម្ពុជា
40. សហព័ន្ធកីឡាអេឡិចត្រូនិច

**គណៈកម្មការជំនាញទាំង១៤**

១. គណៈកម្មការកីឡា និងបទបញ្ញត្តិ
២. គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់
៣. គណៈកម្មការសន្តិសុខនិងសណ្តាប់ធ្នាប់
៤. គណៈកម្មការស្នាក់នៅ ហូបចុក និងដឹកជញ្ជូន
៥. គណៈកម្មការអ្នកស្ម័គ្រចិត្ត
៦. គណៈកម្មការហ្គេមព័ត៌មានវិទ្យា (Games IT)
៧. គណៈកម្មការទីលានប្រកួត
៨. គណៈកម្មការវេជ្ជសាស្ត្រ និងដូពីង
៩. គណៈកម្មការវប្បធម៌ បរិស្ថាន អប់រំនិងកីឡា
១០. គណៈកម្មការផ្សព្វផ្សាយ និងព័ត៌មាន
១១. គណៈកម្មការទីផ្សារ និងចលនូបត្ថម្ភ
១២. គណៈកម្មការពិធីការ និងបដិសណ្ឋារកិច្ច
១៣. គណៈកម្មការពិធីបើក និងបិទ
១៤. លេខាធិការដ្ឋាន គ.ជ.ប.អ.

**គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា**

**គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា**

**មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា**

## ផ្នែកទី ៥ នីតិវិធីនៃការគ្រប់គ្រងថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣

### ៥.១ គោលការណ៍រួមសម្រាប់ការគ្រប់គ្រងថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ២០២៣

ក្នុងគោលដៅធានាសម្រេចឱ្យបាននូវយុទ្ធសាស្ត្រ «**សន្សំសំចៃ ប៉ុន្តែផ្តល់នូវការប្រកួតដ៏អស្ចារ្យ**» សម្រាប់ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជារាជរដ្ឋាភិបាល កំណត់ថា ថវិកានៃមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ត្រូវបានចំណាយក្នុងគោលដៅធានាឱ្យសកម្មភាពការងារ ដើម្បីត្រៀម និងរៀបចំប្រកួតកីឡាស៊ីហ្គេមលើកទី ៣២ ឆ្នាំ២០២៣ ទទួលបានការផ្គត់ផ្គង់គ្រប់គ្រាន់ ទាន់ពេលវេលា ចំទិសដៅ និងធានាបាននូវប្រសិទ្ធភាពប្រតិបត្តិការ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ (គ.ជ.ប.អ.) បានចាត់ទុកថា ការងាររៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ គឺជាការអនុវត្តគម្រោងជាតិមួយ ដោយមានវិសាលភាពគ្របដណ្តប់ទូលំទូលាយ និងមានអ្នកពាក់ព័ន្ធច្រើន ។ ដូច្នេះ នីតិវិធីគ្រប់គ្រងថវិកានិងធនធានរបស់ គ.ជ.ប.អ. ចាំបាច់ត្រូវតែមានភាពទន់ភ្លន់ និងសាមញ្ញ ឆ្លើយតបទាន់ពេលវេលានូវតម្រូវការជាក់ស្តែង ដោយកាត់បន្ថយវំហូរការងារឱ្យនៅត្រឹមកម្រិតអប្បបរមា ប៉ុន្តែរក្សាបាននូវអភិបាលកិច្ចល្អ ។

ដោយផ្អែកលើបរិការណ៍ដូចបានគូសរំលេចខាងលើ, ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈប្រកាសលេខ ៧២៦ សហវ.ប្រក ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាន និងនីតិវិធីអនុវត្តចំណាយមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣, បានសម្រេចជាគោលការណ៍ជូនគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣(គ.ជ.ប.អ.) នូវសិទ្ធិស្វ័យសម្រេច និងការទទួលខុសត្រូវពេញលេញលើការអនុវត្តចំណាយ ដោយត្រូវចាត់ចែងចំណាយដែលទទួលបានពីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ។ ក្នុងន័យនេះ រាល់មុខសញ្ញាចំណាយនីមួយៗដែលមានក្នុងផែនការចំណាយប្រចាំឆ្នាំ និងទទួលបានការឯកភាពជាគោលការណ៍ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ ត្រូវបានអនុញ្ញាតជាអាទិ៍ដូចខាងក្រោម ៖

- អនុញ្ញាតឱ្យផ្ទេរប្រាក់ចេញពីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ទៅគណនីរបស់ គ.ជ.ប.អ. នៅធនាគារ សម្រាប់បើកផ្តល់ជូនអង្គភាពប្រតិបត្តិ បុគ្គលពាក់ព័ន្ធ និងទូទាត់ជូនអ្នកផ្គត់ផ្គង់
- មិនតម្រូវឱ្យមានការស្នើសុំធានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈ ដោយមិនកំណត់ទឹកប្រាក់ ប៉ុន្តែត្រូវមានការចូលរួមរបស់គណៈកម្មការផ្គត់ផ្គង់ហិរញ្ញវត្ថុ និងផ្គត់ផ្គង់
- ចំណាយផ្សេងៗដែលមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្ម ត្រូវអនុវត្តដោយអនុលោមតាមគោលរបប និងគោលការណ៍ដែលបានកំណត់រវាង គ.ជ.ប.អ. និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុញ្ញាតឱ្យរក្សាទុកសមតុល្យសាច់ប្រាក់នៅចុងឆ្នាំ ដើម្បីអនុវត្តចំណាយនៅឆ្នាំបន្ទាប់ សម្រាប់សកម្មភាពដែលបានគ្រោងក្នុងផែនការ និងទទួលបានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ និងសម្រាប់សកម្មភាពថ្មីតាមការសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ៥.២ ការកសាងផែនការថវិកា និងធនធានសម្រាប់ គ.ជ.ប.អ.

### ៥.២.១. សារៈសំខាន់នៃការកសាងផែនការ

ការកសាងផែនការដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងសមាហរណកម្ម គឺមានសារសំខាន់ណាស់ ក្នុងការជួយឱ្យគណៈកម្មការផ្គត់ផ្គង់និងហិរញ្ញវត្ថុ អាចឆ្លើយតបទៅនឹងសំណើរបស់អង្គភាពប្រតិបត្តិបានគ្រប់គ្រាន់ ទាន់ពេលវេលា ចំទិសដៅ និងសន្សំសំចៃ ។ ម៉្យាងទៀត ការណ៍នេះអាចរួមចំណែកធ្វើឱ្យការគ្រប់គ្រង និងចាត់ចែងប្រើប្រាស់ថវិកា និងធនធានគ្រប់ប្រភេទសម្រាប់ការរៀបចំការប្រកួតកីឡា ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពជាពិសេស ដើម្បីជួយឱ្យគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ មានពេលវេលាគ្រប់គ្រាន់ ក្នុងការអនុវត្តនីតិវិធីហិរញ្ញវត្ថុបានត្រឹមត្រូវ និងសមស្រប ។

### ៥.២.២. ក្របខ័ណ្ឌពេលវេលា

ដើម្បីឱ្យមានស្តង់ដារួម ក្របខ័ណ្ឌពេលវេលានៃការកសាងផែនការថវិកា និងធនធាន សម្រាប់ គ.ជ.ប.អ. គឺយកឆ្នាំថវិកាជាមូលដ្ឋាន ។

### ៥.២.៣. មូលដ្ឋាននៃការកសាងផែនការ

- ការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ និងផែនការចំណូល-ចំណាយប្រចាំឆ្នាំ ត្រូវផ្អែកលើផែនការមេ ឆ្នាំ ២០១៩-២០២៣ នៃដំណើរឆ្ពោះទៅការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ ដែលទទួលបានការអនុម័តពី គ.ជ.ប.អ. ។
- រាល់គម្រោងចំណាយទាំងអស់ត្រូវគោរពតាមវិសាលភាពនៃប្រសិទ្ធភាព គុណភាព និងគុណផលកីឡា ឆ្ពោះទៅជោគជ័យក្នុងនាមជាម្ចាស់ផ្ទះក្នុងការរៀបចំ SEA Games-ASEAN Para Games ឆ្នាំ ២០២៣ តែប៉ុណ្ណោះ ។
- មុខសញ្ញាចំណាយត្រូវស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចកីឡា ដូចជាចំណាយលើការអភិវឌ្ឍសមត្ថភាព គុណផលកីឡាកម្រិតខ្ពស់ (ក្រុមជម្រើសជាតិ) និងចំណាយលើការរៀបចំព្រឹត្តិការណ៍កីឡា SEA Games-ASEAN Para Games ឆ្នាំ ២០២៣ ។
- ផែនការនេះត្រូវដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យសម្រេច ដោយត្រូវឆ្លុះបញ្ចាំងអំពីតម្រូវការថវិកា និងធនធានទៅតាមមុខសញ្ញានៃគោលដៅប្រើប្រាស់ ព្រមទាំងត្រូវមានភ្ជាប់គម្រោងចំណាយលម្អិតនីមួយៗ បញ្ជាក់អំពីបរិមាណ តម្លៃសមស្រប និងធនធានមនុស្ស សម្រាប់អនុវត្តសកម្មភាព ។

### ៥.២.៤. យន្តការនៃការទទួលខុសត្រូវ

- <u>គណៈកម្មការជំនាញនៃ គ.ជ.ប.អ.</u>

  នៅក្នុងការកសាងផែនការ គណៈកម្មការជំនាញនីមួយៗ អាចមានមុខងារ ២ គឺ ÷

  - មុខងារជាប្រតិបត្តិករនៃថវិកា ដែលត្រូវកសាងផែនការសកម្មភាពនិងផែនការថវិការបស់ខ្លួនផ្ទាល់
  - មុខងារជាអ្នកត្រួតពិនិត្យ ដែលត្រូវទទួលបន្ទុកសម្របសម្រួល និងដឹកនាំអង្គភាពក្រោមឱវាទក្នុងការកសាងផែនការ ។ ជាគោលការណ៍ ក្នុងមុខងារនេះ គណៈកម្មការជំនាញត្រូវសម្របសម្រួល និងដឹកនាំការកសាងផែនការតាមជំនាញរៀងៗខ្លួន ព្រមទាំងផ្តល់អនុសាសន៍ [illegible] របស់អង្គភាពក្រោមឱវាទផងដែរ ។

- **គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិប៉ារ៉ាំឡាំពិកកម្ពុជា, មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា និងសហព័ន្ធកីឡាជាតិ**

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិប៉ារ៉ាំឡាំពិកកម្ពុជា, មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា និងសហព័ន្ធកីឡាជាតិ គឺជាអង្គភាពប្រតិបត្តិដែលអនុវត្តកិច្ចប្រតិបត្តិការផ្ទាល់ ។ ដូច្នេះ ក្នុងការកសាងផែនការប្រតិបត្តិករ មានភារកិច្ចដូចខាងក្រោម ÷

- ត្រូវរៀបចំផែនការសកម្មភាព និងតម្រូវការធនធានដោយត្រូវសហការជាមួយនឹងគណៈកម្មការជំនាញពាក់ព័ន្ធ
- រៀបចំសំណើគម្រោងថវិកា និងធនធានជាសម្ភារ ឧបករណ៍ មធ្យោបាយ ដើម្បីឆ្លើយតបតាមតម្រូវការបន្ទាន់ តម្រូវការប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ និងក្នុងករណីចាំបាច់ របស់អង្គភាពផ្ទាល់ខ្លួន ដោយបែងចែកលម្អិតតាមប្រភេទចំណាយ មុខសញ្ញាចំណាយ និងគោលដៅប្រើប្រាស់ ។

**៥.២.៥. បរិបថការងារ**

បរិបថការងារនៅក្នុងការលើកសំណើផែនការ, ការពិនិត្យនិងផ្តល់អនុសាសន៍, និងការពិនិត្យនិងអនុម័តលើផែនការ (ដ្យាក្រាម ១) មានដូចខាងក្រោម ÷

-គណៈកម្មការជំនាញ និងអង្គភាពនីមួយៗ ត្រូវរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនដោយផ្អែកលើផែនការសកម្មភាពការងារ និងស្របតាមផែនការមេឆ្ពោះទៅកាន់ការរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ (SEA-Games 2023) ហើយត្រូវបញ្ជូនគម្រោងថវិកាប្រចាំឆ្នាំមកគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ មិនឱ្យលើសពីដំណាច់ខែកញ្ញានៃឆ្នាំចរន្ត ដើម្បីពិនិត្យ ប្តូកសរុប និងដាក់ជូនថ្នាក់ដឹកនាំ គ.ជ.ប.អ. តាមឋានានុក្រម ដើម្បីពិនិត្យនិងឯកភាពតាមនីតិវិធីជាធរមាន ។ រាល់គម្រោងថវិកាប្រចាំឆ្នាំរបស់គណៈកម្មការជំនាញ អង្គភាពប្រតិបត្តិ និងអង្គភាពពាក់ព័ន្ធរបស់ គ.ជ.ប.អ. ត្រូវមានការចូលរួមពិគ្រោះយោបល់បច្ចេកទេសជាមួយមន្ត្រីជំនាញនៃគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ និងមន្ត្រីជំនាញលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.អ.ក្នុងករណីចាំបាច់ ។

- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា, គណៈកម្មាធិការជាតិប៉ារ៉ាំឡាំពិកកម្ពុជា, មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា និង សហព័ន្ធកីឡាជាតិ ជាអង្គភាពប្រតិបត្តិ ត្រូវលើកសំណើផែនការស្តីពីតម្រូវការស្នើសុំការគាំទ្រ និងជួយឧបត្ថម្ភពី គ.ជ.ប.អ. តាមរយៈគណៈកម្មការកីឡា និងបទប្បញ្ញត្តិ ។ ករណីនេះ គណៈកម្មការកីឡា និងបទប្បញ្ញត្តិ ត្រូវសម្របសម្រួល និងផ្តល់យោបល់លើផែនការនេះជូនគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ពិនិត្យ ប្តូកសរុប និងដាក់ជូនថ្នាក់ដឹកនាំ គ.ជ.ប.អ. តាមឋានានុក្រម ដើម្បីពិនិត្យនិងឯកភាពតាមនីតិវិធីជាធរមាន ។

- គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ត្រូវប្រមូលផ្តុំ និងពិនិត្យផែនការប្រចាំឆ្នាំពីគណៈកម្មការជំនាញនានា និងអង្គភាពប្រតិបត្តិ ដើម្បីប្តូកសរុប និងរៀបចំជាផែនការរួមមានលក្ខណៈសមាហរណកម្ម ឱ្យបានរួចរាល់ក្នុងសប្តាហ៍ទី២ ខែ វិច្ឆិកា នៃឆ្នាំថវិកា ដើម្បីដាក់ជូនថ្នាក់ដឹកនាំ គ.ជ.ប.អ. ពិនិត្យនិងសម្រេច ។

- គ.ជ.ប.អ. ត្រូវបញ្ជូនគម្រោងថវិកាសរុបប្រចាំឆ្នាំដែលបានទទួលការឯកភាពពីប្រធាន គ.ជ.ប.អ. ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីស្នើសុំពិនិត្យ និងអនុម័ត ជាចុងក្រោយ មិនឱ្យហួសសប្តាហ៍ទី២នៃខែធ្នូឆ្នាំថវិកា ដូចមានបញ្ជាក់ជូនក្នុងដ្យាក្រាម ១ ស្តីពីបរិបថនៃការកសាងផែនការថវិកា និងធនធាន គ.ជ.ប.អ. ។

**ដ្យាក្រាម ១ - បរិបថនៃការកសាងផែនការថវិកា និងធនធាន គ.ជ.ប.អ.**



**៥.៣. ការអនុវត្តចំណាយថវិកា និងការប្រើប្រាស់ធនធានរបស់ គ.ជ.ប.អ.**

ផ្នែកទី៣ បានគូសរំលេចនូវមុខសញ្ញាចំណាយ សម្រាប់គាំទ្រដល់សកម្មភាពរបស់ គ.ជ.ប.អ. ។ មុខសញ្ញាចំណាយទាំងនោះមាននីតិវិធីអនុវត្ត និងបរិបថនៃការស្នើសុំថវិកាខុសៗគ្នា ។ លើសពីនេះ មុខសញ្ញាស្រដៀងគ្នានៃចំណាយ អាចមាននីតិវិធីអនុវត្តនិងបរិបថការងារខុសគ្នា ហើយក៏មានមុខសញ្ញាចំណាយខុសគ្នាខ្លះ អាចមាននីតិវិធីអនុវត្ត និងបរិបថការងារដូចគ្នាទៅវិញដែរ ។ ដូចនេះ ការកំណត់គោលការណ៍ នីតិវិធី និងបរិបថការងារ សម្រាប់អនុវត្តថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ នេះ មិនអនុលោមទៅតាមលំដាប់លំដោយនៃមុខសញ្ញាចំណាយ ដូចដែលបានពន្យល់នៅក្នុងផ្នែកទី៣ ទេ ។ នីតិវិធីនៃការអនុវត្តចំណាយត្រូវបានបែងចែកដូចខាងក្រោម ÷

**៥.៣.១ ចំណាយតាមគោលរបប និងចំណាយតាមសក្ខីបត្រ**

**<u>១- មុខសញ្ញាចំណាយ</u>**

- **ចំណាយតាមគោលរបប** គឺជាចំណាយដែលមានគោលការណ៍ទូទាត់តាមគោលរបបកំណត់ជាមុនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គ.ជ.ប.អ. ដូចជា ចំណាយឧបត្ថម្ភបុគ្គលិក និងការឧបត្ថម្ភផ្សេងៗ, ចំណាយបេសកកម្មនៅក្នុងនិងក្រៅប្រទេស, ចំណាយរៀបចំការបណ្តុះបណ្តាល និងសិក្ខាសាលា, ចំណាយបញ្ជូនអត្តពលិក គ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម ដែលមានគោលរបបកំណត់ ។ល។

- **ចំណាយតាមសក្ខីបត្រ** គឺជាចំណាយមានគោលការណ៍អនុញ្ញាតជាមុនដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទូទាត់ដោយផ្អែកលើសក្ខីបត្រជាក់ស្តែង ដូចជា÷ ចំណាយលើសោហ៊ុយថាមពល, ទឹក, ទូរគមនាគមន៍, សំរាម, សោហ៊ុយជួលទីតាំងដែលមានកិច្ចសន្យាច្បាស់លាស់ដោយមានការទទួលស្គាល់ជាមុនពី គ.ជ.ប.អ., ចំណាយបញ្ជូនអត្តពលិក គ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម ដែលមានវិក្កយបត្រពីប្រទេសម្ចាស់ផ្ទះ ។ល។

**<u>២-នីតិវិធីអនុវត្ត</u>**

- គណៈកម្មការជំនាញនិងអង្គភាពប្រតិបត្តិផ្សេងៗទៀត ត្រូវរៀបចំសំណើសុំទូទាត់ចំណាយលើប្រាក់ឧបត្ថម្ភនិងរបបអាហារតាមគោលការណ៍កំណត់ ស្របតាមតម្រូវការជាក់ស្តែង ដោយភ្ជាប់មកជាមួយនូវសក្ខីបត្រដើម ។ ទោះជាយ៉ាងនេះក្តី នៅពេលបិទបញ្ចប់ប្រតិបត្តិការទាំងស្រុង គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ត្រូវប្រគល់សក្ខីបត្រទាំងអស់ជូនគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាដើម្បីរក្សាទុកជាកម្មវត្ថុនៃការធ្វើសវនកម្ម និងអធិការកិច្ច។ ដូច្នេះ ភាពហ្មត់ចត់ និងការសន្សំសំចៃប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិនីមួយៗ ក្នុងការអនុវត្តចំណាយ ព្រមទាំងសុក្រឹតភាព និងតម្លាភាពនៃការកំណត់មូលដ្ឋានចំណាយសរុប គឺមានសារសំខាន់ណាស់ ។

- ក្នុងករណីចាំបាច់ និងទៅតាមប្រភេទនៃចំណាយ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិពាក់ព័ន្ធ អាចត្រូវបានអនុញ្ញាតឱ្យបើកប្រាក់ទៅតម្កល់ទុកមុនក្នុងទំហំមួយសមស្រប សម្រាប់កិច្ចដំណើរការអង្គភាព ដូចជាចំណាយតូចតាចដូចមានចែងក្នុងចំណុច ៥.៣.២. និងចំណាយផ្សេងទៀតដែលមានគោលរបប និងវិក្កយបត្រច្បាស់លាស់ ដូចមានចែងក្នុងចំណុច ៥.៣.១. ។ ទំហំទឹកប្រាក់ដែលត្រូវផ្តល់ជូននេះ ត្រូវកំណត់ពិតានតាមការសម្រេចរបស់ប្រធាន គ.ជ.ប.អ. ផ្អែកលើសំណើរបស់គណៈកម្មការជំនាញ តាមរយៈអគ្គលេខាធិការដ្ឋាន គ.ជ.ប.អ. និងដោយមានការផ្តល់យោបល់ពីគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ។ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ អាចត្រូវបានអនុញ្ញាតឱ្យបើក[illegible]

របស់ខ្លួនសម្រាប់រក្សាទុកសាច់ប្រាក់សម្រាប់កិច្ចប្រតិបត្តិការខ្លួនឯងផង និងសម្រាប់ទម្លាក់ទៅឱ្យអង្គភាពប្រតិបត្តិក្រោមឱវាទផង ។ ក្នុងករណីនេះ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវរៀបចំបែបបទទូទាត់ជម្រះចំណាយដែលបានអនុវត្តរួច ដើម្បីទទួលបានសាច់ប្រាក់ជាថ្មីទៅបំពេញឡើងវិញ ។ ការអនុវត្តនិតិវិធីចំណាយនេះ ត្រូវអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ ។ ទឹកប្រាក់ដែលបំពេញបេឡាឡើងវិញ គឺមិនត្រូវលើសពីចំនួនដែលបានទូទាត់ និងមិនត្រូវលើសពីពិតានទឹកប្រាក់កំណត់ទេ ។ ក្រោយពីបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនទាំងស្រុង គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវបិទគណនីធនាគារ និងត្រូវបង្វែរសមតុល្យសាច់ប្រាក់ដែលនៅសល់មកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់វិញ ដើម្បីជម្រះបញ្ជី ។

**<u>៣- បរិបថការងារ</u>**

- គណៈកម្មការជំនាញ ត្រូវបានអនុញ្ញាតឱ្យលើកសំណើសុំត្រង់ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.អ.។ ចំណែកអង្គភាពក្រោមឱវាទ ត្រូវលើកសំណើសុំទូទាត់តាមរយៈគណៈកម្មការជំនាញដែលជាអាណាព្យាបាល ។ ដោយឡែកអង្គភាពប្រតិបត្តិ ត្រូវលើកសំណើទូទាត់តាមរយៈគណៈកម្មការកីឡា និងបទប្បញ្ញត្តិ ។ រាល់សំណើសុំទូទាត់ ត្រូវមានភ្ជាប់មកជាមួយនូវគម្រោងចំណាយ ឬរបាយការណ៍ចំណាយ និងឯកសារគាំទ្រគ្រប់គ្រាន់និងត្រឹមត្រូវ ។
- គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ ហើយបន្ទាប់ពីមានការឯកភាពពីអគ្គលេខាធិការ គ.ជ.ប.អ. ត្រូវរៀបចំបើកផ្តល់ដល់គណនីបុគ្គល ឬអ្នកផ្គត់ផ្គង់ផ្ទាល់ ឬទៅដល់អង្គភាពប្រតិបត្តិ ទៅតាមប្រភេទចំណាយជាក់ស្តែង ។

**<u>៤- យន្តការប្រតិទុល្យការ</u>**

គណៈកម្មការជំនាញនីមួយៗ ជាពិសេសគណៈកម្មការកីឡា និងបទប្បញ្ញត្តិ ក្នុងតួនាទីជាអ្នកដឹកនាំនិងសម្របសម្រួលអង្គភាពក្រោមឱវាទ និងអង្គភាពប្រតិបត្តិ ដើម្បីជួយតម្រែតម្រង់លើការអនុវត្តចំណាយ គឺមានសារសំខាន់ណាស់ ដែលការណ៍នេះអាចនឹងមានឥទ្ធិពលសំខាន់ទៅលើប្រសិទ្ធផល និងគុណផលកីឡា ក៏ដូចជាការសន្សំសំចៃថវិកាផងដែរ ។

**៥.៣.២ ចំណាយតូចតាច**

**<u>១- ប្រភេទនិងមុខសញ្ញា</u>**

ចំណាយតូចតាច គឺសំដៅដល់ចំណាយដែលមានទឹកប្រាក់តិចតួច និងមិនអាចគ្រោងទុកមុន ដែលត្រូវដោះស្រាយភ្លាមៗ ដូចជា ចំណាយលើការជួសជុលនិងថែទាំតូចតាច, ការទិញទំនិញនិងសេវាតូចតាចនិងតិចតួច, ចំណាយផ្សេងៗលើកិច្ចការរដ្ឋបាល ជាដើម ។ ការបង្កើតខ្ទង់ចំណាយនេះ គឺដើម្បីផ្តល់ភាពទន់ភ្លន់ខាងនីតិវិធី ក្នុងកម្រិតពិតានទឹកប្រាក់សរុបកំណត់មួយ សម្រាប់គណៈកម្មការជំនាញនិងអង្គភាពក្រោមឱវាទ និងអង្គភាពប្រតិបត្តិ ។

**<u>២- នីតិវិធីអនុវត្ត</u>**

ចំណាយប្រភេទនេះ ជាចំណាយតូចតាច និងត្រូវបានកំណត់ទឹកប្រាក់ ៣ (បី) លានរៀល ជាអតិបរមា ក្នុងមួយគោលការណ៍ចំណាយ ឬមួយប័ណ្ណចំណាយ ។ គណៈកម្មការកីឡា និងបទប្បញ្ញត្តិ ត្រូវវាយតម្លៃអង្គភាពប្រតិបត្តិដើម្បីទទួលបានសិទ្ធិអនុវត្តចំណាយតាមនីតិវិធីនេះ ។ ការអនុវត្តនីតិវិធីចំណាយតូចតាចត្រូវអនុលោមតាមយន្តការជុំបង្វិល និងការបំពេញបេឡាឡើងវិញ ។ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវរៀបចំរបាយការណ៍ចំណាយ ([illegible]) ដោយមានការបញ្ជាក់ទទួលស្គាល់ដោយប្រធានគណៈកម្មការជំនាញ និងប្រធានអង្គភាពប្រតិបត្តិ ដើម្បីទូទាត់ចំណាយ ។ ទោះជា

យ៉ាងនេះក្តី ក្រោយពីបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនទាំងស្រុង, សក្ខីបត្រទាំងនេះត្រូវប្រមូលនិងប្រគល់ជូនគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជារក្សាទុក សម្រាប់ជាកម្មវត្ថុនៃការធ្វើសវនកម្ម និងអធិការកិច្ច ហើយអង្គភាពប្រតិបត្តិត្រូវបង្វែរសមតុល្យសាច់ប្រាក់ដែលនៅសល់មកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់វិញ ដើម្បីជម្រះបញ្ជី ។

<u>៣-បរិបថការងារ</u>

ស្របតាមគោលការណ៍កំណត់, ការបើកសាច់ប្រាក់លើកដំបូងត្រូវបានបង្វែរជាស្វ័យប្រវត្តិ ចូលទៅគណនីរបស់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិដែលមានសិទ្ធិ ។ ចំពោះការទម្លាក់សាច់ប្រាក់ជាបន្តបន្ទាប់ គឺត្រូវអនុលោមតាមយន្តការជុំបង្វិល និងបំពេញបេឡាឡើងវិញ ។ ក្នុងន័យនេះ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិត្រូវរៀបចំរបាយការណ៍ចំណាយ (SOE) ដែលមានបញ្ជាក់ទទួលស្គាល់ដោយប្រធានគណៈកម្មការជំនាញ និងប្រធានអង្គភាពប្រតិបត្តិ និងស្នើសុំការទូទាត់ ដើម្បីបំពេញបេឡា ។ ដើម្បីនិរន្តរភាពការងារ ការទូទាត់ចំណាយតូចតាចត្រូវបានអនុញ្ញាតឱ្យធ្វើឡើងច្រើនលើកក្នុងមួយខែ ដោយមិនត្រូវឱ្យអស់សាច់ប្រាក់ទេ ។

<u>៤-គណនេយ្យភាព</u>

ប្រធានគណៈកម្មការជំនាញ និងប្រធានអង្គភាពប្រតិបត្តិ ត្រូវចាត់ចែងអនុវត្តថវិកាស្របតាមគោលការណ៍កំណត់ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

**៥.៣.៣ ចំណាយជាកម្មវត្ថុនៃកិច្ចលទ្ធកម្ម**

<u>១- មុខសញ្ញាចំណាយ</u>

ចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម មានទាំងប្រភេទចំណាយប្រចាំ និងចំណាយមិនប្រចាំ <u>(ដូចមានរៀបរាប់លម្អិតក្នុងផ្នែកទី៣)</u> ។ ចំណាយទាំងនេះ គឺតម្រូវឱ្យមានផែនការប្រតិបត្តិការច្បាស់លាស់ ទាំងកម្រិតប្រតិបត្តិការ ទាំងកម្រិតយុទ្ធសាស្ត្រ ដើម្បីធានាឱ្យការផ្គត់ផ្គង់គ្រប់គ្រាន់ ទាន់ពេលវេលា មានប្រសិទ្ធភាព និងមិនខ្ជះខ្ជាយ ។

<u>២-បរិបថការងារ</u>

-គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ អាចលើកសំណើសម្រាប់មួយករណីម្តងៗ ឬប្រមូលផ្តុំចំណាយតាមសកម្មភាពការងារ ។ លិខិតស្នើសុំគោលការណ៍ចំណាយត្រូវភ្ជាប់មកជាមួយនូវគម្រោងចំណាយដែលពន្យល់ពីតម្រូវការចំណាយ និងប្រភេទចំណាយ ។

-ចំពោះសំណើដែលមានគ្រោងក្នុងផែនការដែលបានអនុម័តរួច (ដ្យាក្រាម ២.១) គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ដែលគ្រប់គ្រងការងារតាមផ្នែកនីមួយៗ នៃ គ.ជ.ប.អ. អាចលើកសំណើមកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដោយចម្លងជូនក្រុមការងាររៀបចំថវិកាសម្រាប់ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ដើម្បីជ្រាបជាព័ត៌មាន ។ ចំពោះសំណើរបស់អង្គភាពប្រតិបត្តិ ត្រូវឆ្លងការត្រួតពិនិត្យនិងឯកភាពពីគណៈកម្មការកីឡា និងបទប្បញ្ញត្តិជាមុនសិន មុននឹងបញ្ជូនមកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ។ ចំណាយដែលមានគ្រោងក្នុងផែនការដែលបានអនុម័តរួច និងមានទឹកប្រាក់អតិបរមា **ពីរប៊ីលានរៀល** ក្នុងមួយគម្រោងចំណាយ ត្រូវសម្រេចអនុម័តដោយអគ្គលេខាធិការ គ.ជ.ប.អ. ។ ដោយឡែក ចំណាយដែលមានទឹកប្រាក់លើសពី ពីរប៊ីលានរៀល ត្រូវឆ្លងការពិនិត្យនិងសម្រេចអនុម័តដោយប្រធាន គ.ជ.ប.អ. ។ ដោយឡែក ប្រធានគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់អាចប្រគល់សិទ្ធិជូនប្រធានលេខាធិការដ្ឋាន

នៃគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ក្នុងការពិនិត្យ និងផ្តល់យោបល់ និងបញ្ជូនបន្តតាមឋានានុក្រម សម្រាប់សំណើ ដែលមានទឹកប្រាក់អតិបរមាប្រាំរយលានរៀល ។

-ចំពោះសំណើដែលមិនមានក្នុងផែនការដែលបានអនុម័តរួច (ដ្យាក្រាម ២.២), គ.ជ.ប.អ. ត្រូវស្នើសុំការអនុម័ត ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនពេលចាប់ផ្តើមអនុវត្តចំណាយ ។ ក្នុងករណីចាំបាច់បន្ទាន់ សំណើពីគណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ អាចត្រូវបានពិនិត្យនិងសម្រេចដោយត្រង់និងដោយផ្ទាល់ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមយោបល់របស់ប្រធានគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ។

-ក្នុងករណីពិនិត្យឃើញថា សំណើរបស់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ មានលក្ខណសម្បត្តិគ្រប់គ្រាន់, គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ អាចនឹងពិនិត្យស្នើដោះស្រាយជូនតាមលទ្ធភាពពីរយ៉ាងគឺ÷ (១) ចាត់ចែងអនុវត្ត នីតិវិធីលទ្ធកម្មតាមករណីនីមួយៗ (២) បើកផ្តល់ថវិកាបុរេប្រទានជូនដល់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ដើម្បីយកទៅអនុវត្ត ។

-ចំពោះការផ្តល់ថវិកាបុរេប្រទាន ក្នុងករណីដែលសាច់ប្រាក់បុរេប្រទាន មិនគ្រប់គ្រាន់សម្រាប់បញ្ចប់គម្រោង គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ អាចស្នើសុំមកអគ្គលេខាធិការនៃគ.ជ.ប.អ. តាមរយៈគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់តាមនីតិវិធីជាធរមាន ដើម្បីទូទាត់ថវិកាដែលបានចំណាយរួច និងស្នើសុំថវិកាបង្គ្រប់ ដើម្បីទូទាត់បញ្ចប់គម្រោង ដោយត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយ របាយការណ៍វឌ្ឍនភាពការងារ ព្រមទាំងលិខិតយុត្តិការពាក់ព័ន្ធ ។ ដោយឡែក ក្នុងករណីដែលនៅសល់ថវិកាបុរេប្រទានក្រោយអនុវត្តគម្រោងចប់សព្វគ្រប់, គណៈកម្មការជំនាញ និងអង្គ-ភាពប្រតិបត្តិ ត្រូវបង្វែរថវិកាដែលនៅសល់នោះមកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដោយមិនអនុញ្ញាតឱ្យទុកសាច់ប្រាក់ដែលនៅសល់នោះដើម្បីអនុវត្តគម្រោង ឬមុខចំណាយផ្សេងទៀតឡើយ ។ ថវិកាបុរេប្រទាន គឺជាថវិកាដែលត្រូវយកទៅចំណាយជាបន្ទាន់ ត្រូវការសាច់ប្រាក់មុន និងមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីអនុវត្តនីតិវិធីធម្មតាបាន ។

-ការដោះស្រាយសំណើចំណាយរបស់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ គឺជាកម្មវត្ថុនៃការសម្រេចដោយប្រធាន គ.ជ.ប.អ. ឬអគ្គលេខាធិការ គ.ជ.ប.អ. តាមមតិយោបល់របស់ប្រធានគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ តាមទំហំទឹកប្រាក់ដែលមានចែងខាងលើ ។

-ការអនុវត្តកិច្ចលទ្ធកម្មគឺជាតួនាទី និងភារកិច្ចរបស់ក្រុមលទ្ធកម្មនៃ គ.ជ.ប.អ. ទោះបីជាប្រើប្រាស់ថវិកាបុរេប្រទានក៏ដោយ ។

-ការបើកផ្តល់ថវិកា ឬធនធានផ្សេងទៀត ត្រូវអនុវត្តដោយត្រង់ពីគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ទៅគណៈកម្មការជំនាញ អង្គភាពប្រតិបត្តិ និងអ្នកផ្គត់ផ្គង់ ។

រំហូរនៃការស្នើសុំចំណាយថវិកា មានក្នុងដ្យាក្រាមដូចខាងក្រោម ÷



ដ្យាក្រាម ២.១. សំណើដែលមានគ្រោងក្នុងផែនការ



ដ្យាក្រាម ២.២. សំណើដែលមិនមានគ្រោងក្នុងផែនការ



**៥.៤. ការគ្រប់គ្រងចំណូល**

ការប្រមូលចំណូលគឺជាតួនាទីជាចម្បងរបស់គណៈកម្មការទីផ្សារកីឡា និងចលនូបត្ថម្ភ ដោយត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសិក្សាពីប្រភពចំណូល យន្តការស្វែងរក និងការគ្រប់គ្រងចំណូលសំដៅកាត់បន្ថយបន្ទុកចំណាយ និងជំរុញការគ្រប់គ្រងចំណូលប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ។ ចំណូលពីគ្រប់ប្រភព ត្រូវទទួល កត់ត្រា និងគ្រប់គ្រងដោយគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ។ ចំណូលខាងលើអាចយកទៅប្រើប្រាស់មួយផ្នែកសម្រាប់ឧបត្ថម្ភលើកទឹកចិត្តដល់គណៈកម្មាធិការ គណៈកម្មការ និងក្រុមការងារជួរមុខតាមការចាំបាច់ តាមគោលការណ៍កំណត់របស់ប្រធាន គ.ជ.ប.អ., មួយផ្នែកទៀតសម្រាប់ដោះស្រាយតម្រូវការចំណាយជាក់ស្ដែងដើម្បីជួយសម្រាលបន្ទុកថវិការដ្ឋសម្រាប់រៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ និងផ្នែកដែលនៅសល់ជាកម្មវត្ថុនៃការបង់ចូលថវិការដ្ឋ ។ ការដកយកចំណូលសម្រាប់ប្រើប្រាស់ក្នុងមុខសញ្ញាចំណាយណាក៏ដោយត្រូវសុំគោលការណ៍ជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ យន្តការនៃការគ្រប់គ្រងចំណូលត្រូវអនុវត្តតាមបទដ្ឋានគតិយុត្តដែលមានជាធរមាន ។

**ផ្នែកទី៦ ការគ្រប់គ្រងឃ្លាំង សន្និធិ និងទ្រព្យសម្បត្តិ**

សន្និធិ និងទ្រព្យសម្បត្តិដែលប្រើប្រាស់ដោយគណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ដែលទទួលបានមកពីការប្រើប្រាស់ថវិកា និងធនធានមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ និងប្រភពផ្សេងទៀត ត្រូវរៀបចំ កត់ត្រា និងគ្រប់គ្រងដោយអនុលោមតាមបទប្បញ្ញត្តិគតិយុត្តជាធរមាន ។

**៦.១. ការគ្រប់គ្រងឃ្លាំង និងសន្និធិ**

**៦.១.១. អំពីឃ្លាំង**

ឃ្លាំងស្តុកគឺជាផ្នែកមួយនៃខ្សែសង្វាក់ព័ស្តុភារកម្ម ដែលផ្តល់ជូនអង្គភាពនូវអន្តរកម្មពេញលេញក្នុងការអនុវត្តដំណើរការបំពេញមុខងារផ្គត់ផ្គង់ ការស្តុកទុក ការគ្រប់គ្រង និងការប្រើប្រាស់ធនធាន ចាប់តាំងពីពេលស្តុកចូល និងចែកចាយ ។

គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវគិតគូរជ្រើសរើសទីតាំងភូមិសាស្ត្រដែលមានចម្ងាយជិតបំផុត ហើយផ្លូវដឹកជញ្ជូនមានប្រសិទ្ធភាពបំផុត ដើម្បីឱ្យងាយស្រួលក្នុងការធ្វើចលនាទំនិញចេញ-ចូលឃ្លាំង និងត្រូវគិតគូរអំពីទំហំឃ្លាំង គុណភាពនៃសំណង់ឃ្លាំង ព្រមទាំងការគ្រប់គ្រងហានិភ័យ និងការត្រៀមបម្រុងទុកដើម្បីស្វែងរកដំណោះស្រាយជម្រើសជំនួសឃ្លាំង ។

**៦.១.២. អំពីសន្និធិ**

សន្និធិ ជាទ្រព្យសកម្ម មានទម្រង់ជាសម្ភារ ឧបករណ៍ មធ្យោបាយ ដែលត្រូវបានបម្រុងទុកសម្រាប់ដំណើរការ ឬក្នុងការផ្តល់សេវា បម្រើឱ្យសកម្មភាពរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ ។ សន្និធិ ត្រូវបានទទួលស្គាល់ ក្រោមវត្តមានសមាជិកក្រុមការងារផ្នែកផ្គត់ផ្គង់ចំណុះឱ្យគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ និងកត់ត្រាតាមតម្លៃជាក់ស្តែងក្នុងវិក្កយបត្របញ្ចូលឃ្លាំង ។

គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវគ្រប់គ្រងសន្និធិឱ្យបានច្បាស់លាស់ ពេលមានចលនាទំនិញចេញ ឬចូល វាយតម្លៃអំពីតម្រូវការសន្និធិ និងប៉ាន់ស្មានអំពីរយៈពេលនៃការបញ្ជាទិញ ដើម្បីបំពេញសមតុល្យ ដើម្បីងាយស្រួលនៅក្នុងការធ្វើគម្រោងផែនការថ្មី និងដឹងអំពីភាពខ្វះខាតរបស់សន្និធិ ដើម្បីធ្វើការបញ្ជាទិញបានទាន់ពេលវេលា ។ ជាមួយគ្នានេះ ត្រូវដឹងពីស្ថានភាពដែលអាចប្រើប្រាស់បានពិតប្រាកដរបស់សន្និធិ ដូចជា សម្ភារ ឧបករណ៍ មធ្យោបាយ ដែលខូចខាត បាត់បង់ ឬខូចគុណភាព ។

គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ត្រូវមានវិធីសាស្ត្រច្បាស់លាស់ក្នុងការត្រួតពិនិត្យសន្និធិជាក់ស្តែង ឱ្យបានទៀងទាត់ និងត្រូវផ្ទៀងផ្ទាត់ជាប្រចាំ រវាងកំណត់ត្រាចេញ-ចូលនិងសមតុល្យជាមួយនឹងសន្និធិជាក់ស្តែង ដើម្បីធានាថាសន្និធិត្រូវបានរក្សាទុក និងគ្រប់គ្រងត្រឹមត្រូវ ច្បាស់លាស់ មានការទទួលខុសត្រូវខ្ពស់ ការពារបាននូវការបាត់បង់ ឬខូចខាតជាយថាហេតុ ហើយម្យ៉ាងទៀតដើម្បីធានាថាការផ្គត់ផ្គង់បានគ្រប់គ្រាន់ត្រឹមត្រូវ និងទាន់ពេលវេលា ។ ក្នុងករណីមានការខូចខាត ឬ បាត់បង់សន្និធិ ជាយថាហេតុ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិត្រូវរាយការណ៍មកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដើម្បីបូកសរុបនិងរាយការណ៍បន្តជូន ប្រធាន គ.ជ.ប.អ. ដើម្បីចាត់វិធានការតាមនីតិវិធី ។

យន្តការនៃការគ្រប់គ្រងសន្និធិ គឺគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិត្រូវធ្វើការកត់ត្រាចលនាចេញ-ចូល ដោយបែងចែកសន្និធិដែលប្រើប្រាស់ថវិកាពីប្រភពខុសគ្នា ដូចជា ប្រភពថវិកា និងធនធានមកពីថវិកាថ្នាក់ជាតិ ថវិកាមកពីប្រភពផ្សេងៗ ដើម្បីតាមដានសមតុល្យច្បាស់លាស់តាមប្រភពធនធាន ។

### ៦.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិរបស់គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ដែលទទួលបានតាមរយៈការប្រើប្រាស់ថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ត្រូវរៀបចំ កត់ត្រាក្នុងសៀវភៅបញ្ជីសារពើភណ្ឌ ដោយកត់ត្រាលម្អិតនូវទ្រព្យសម្បត្តិទាំងអស់ជាចលនទ្រព្យ និងអចលនទ្រព្យ ព្រមទាំងត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ។ ការកត់ត្រានេះ ត្រូវអនុវត្តភ្លាមនៅពេលទទួលបានទ្រព្យសម្បត្តិ ។ បន្ទាប់មក គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ត្រូវតាមដានជាប្រចាំនូវចលនាកើនឡើង-ថយចុះនៃទ្រព្យសម្បត្តិក្នុងតារាងតាមដានកើនឡើងនិងថយចុះនូវទ្រព្យសម្បត្តិ ។

បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ត្រូវឆ្លុះបញ្ចាំងជាប្រចាំនូវព័ត៌មានជាក់ស្តែង និងពិតប្រាកដនៃទ្រព្យសម្បត្តិដែលស្ថិតក្រោមការកាន់កាប់របស់ខ្លួន ។ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិត្រូវកត់ត្រាជាអាទិ៍ តាមប្រភេទ លក្ខណៈ តម្លៃ ប្រភពធនធាន ទីតាំង និងស្ថានភាពនៃទ្រព្យសម្បត្តិនោះ ។

គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ត្រូវមានយន្តការក្នុងការត្រួតពិនិត្យជាក់ស្តែងលើទ្រព្យសម្បត្តិដើម្បីធានាថាទ្រព្យសម្បត្តិទាំងអស់ត្រូវបានគ្រប់គ្រងត្រឹមត្រូវ ច្បាស់លាស់ ចៀសវាងបាននូវការបាត់បង់ ឬខូចខាតជាយថាហេតុ ។ ការត្រួតពិនិត្យជាក់ស្តែងអាចអនុវត្តប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ និងតាមការចាំបាច់ ។ ដើម្បីឱ្យការត្រួតពិនិត្យជាក់ស្តែងលើទ្រព្យសម្បត្តិមានភាពងាយស្រួល និងជាប្រព័ន្ធ ត្រូវរៀបចំកំណត់កូដសម្រាប់ទ្រព្យសម្បត្តិនីមួយៗ ទៅតាមប្រភេទ ប្រភពធនធាន និងទីតាំងប្រើប្រាស់ ។

គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ត្រូវរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការរៀបចំនិងការកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ ជូនគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដើម្បីបូកសរុប ។ ជាមួយគ្នានេះ ត្រូវពិនិត្យនិងវាយតម្លៃទ្រព្យសម្បត្តិ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឬជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយត្រូវអនុវត្តតាមនីតិវិធីជាធរមាន ។

ក្នុងករណីមានការខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ ជាយថាហេតុ គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ត្រូវរាយការណ៍ជូនគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ដើម្បីបូកសរុប និងរាយការណ៍បន្តជូនប្រធាន គ.ជ.ប.អ. ដើម្បីចាត់វិធានការតាមនីតិវិធី ។

គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ ត្រូវរៀបចំបាយការណ៍ជូនគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ដើម្បីបូកសរុប និងដាក់ជូនប្រធាន គ.ជ.ប.អ. ពិនិត្យ ។

នៅក្រោយការបិទបញ្ចប់ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣ គ.ជ.ប.អ. ត្រូវបង្កើតគណៈកម្មការដើម្បីវាយតម្លៃសន្និធិ និងទ្រព្យសម្បត្តិទាំងអស់ និងចាត់វិធានការតាមគោលការណ៍ និងនីតិវិធី ។

**ផ្នែកទី៧. របបរបាយការណ៍**

គណៈកម្មការជំនាញ និងអង្គភាពប្រត្តិបត្តិ គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ មានកាតព្វកិច្ចរៀបចំរបាយការណ៍ស្តីពីការប្រើប្រាស់ថវិកា និងគ្រប់គ្រងធនធានសម្ភារ ឧបករណ៍ មធ្យោបាយនានា រួមមានរបាយការណ៍ស្តីពីការអនុវត្តថវិកា (របាយការណ៍ចំណូល-ចំណាយថវិកា និងរបាយការណ៍លទ្ធផលការងារ ) របាយការណ៍សន្និធិ របាយការណ៍ទ្រព្យសម្បត្តិ និងរបាយការណ៍ផ្សេងទៀត តាមការចាំបាច់ ។ ការរៀបចំ និងផ្ញើរបាយការណ៍ត្រូវអនុវត្តជារៀងរាល់ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ឬតាមការចាំបាច់ ។ ជានីតិវិធី គ្រប់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវរៀបចំរបាយការណ៍ដើម្បីផ្ញើជូនគណៈកម្មការហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ដើម្បីបូកសរុបជារបាយការណ៍រួម និងមានលក្ខណៈសមាហរណកម្មដើម្បីដាក់ជូនប្រធាន គ.ជ.ប.អ. ពិនិត្យតាមឋានានុក្រម ។

គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ត្រូវរាយការណ៍ឱ្យបានទៀងទាត់ ជាប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ឬតាមការចាំបាច់ ដូចខាងក្រោម ÷

ក. របាយការណ៍ជូនប្រធាន គ.ជ.ប.អ. ស្តីពីការផ្គត់ផ្គង់ទាំងថវិកា និងធនធានជាសម្ភារ ឧបករណ៍ មធ្យោបាយ ដែលបានផ្តល់ជូនគណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ។

ខ. របាយការណ៍ជូនប្រធាន គ.ជ.ប.អ. ស្តីពីសមតុល្យសន្និធិ ។

**៧.១. របាយការណ៍អនុវត្តថវិកា**

របាយការណ៍អនុវត្តថវិកា គឺជាឧបករណ៍យ៉ាងសំខាន់សម្រាប់ផ្តល់ព័ត៌មាន និងសម្រាប់ធ្វើជាមូលដ្ឋានវាយតម្លៃលទ្ធផលសម្រេចបាន ទាំងទិដ្ឋភាពហិរញ្ញវត្ថុ ទាំងទិដ្ឋភាពលទ្ធផល ធៀបនឹងផែនការមេ ។ ទន្ទឹមនឹងនេះ របាយការណ៍នេះគឺជាមូលដ្ឋានសម្រាប់ការតាមដានត្រួតពិនិត្យលទ្ធផលនៃការអនុវត្ត មានគោលបំណងតម្រង់ទិស កែតម្រូវ បំពេញតម្លៃបន្ថែម បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃប្រតិបត្តិការចំណាយថវិកាសម្រាប់ការរៀបចំព្រឹត្តិការណ៍ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ ព្រមទាំងសម្រាប់រៀបចំផែនការសកម្មភាពសម្រាប់អនុវត្តជាបន្តបន្ទាប់ដែរ ។ របាយការណ៍អនុវត្តថវិកាមានពីរប្រភេទ គឺ ÷

### ៧.១.១. របាយការណ៍ចំណូល-ចំណាយថវិកា

របាយការណ៍អនុវត្តថវិកា ឆ្លុះបញ្ចាំងអំពីកិច្ចដំណើរការដែលគណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ គ្រប់គ្រង និងចាត់ចែងថវិកា ដោយត្រូវបង្ហាញពីការវិភាគអំពីស្ថានភាពអនុវត្តថវិកាតាមប្រភេទចំណាយ មុខសញ្ញាចំណាយ និងប្រភពធនធាន ។

គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ តម្រូវឱ្យធ្វើរបាយការណ៍តាមគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍នីមួយៗ ។ របាយការណ៍ចំណូល-ចំណាយ ត្រូវរៀបចំ និងផ្ញើមកអនុគណៈកម្មការផ្គត់ផ្គង់និងហិរញ្ញវត្ថុតាមកាលបរិច្ឆេទកំណត់ជាក់លាក់ប្រចាំត្រីមាស ឬតាមតម្រូវការចាំបាច់ ។

### ៧.១.២. របាយការណ៍លទ្ធផលការងារ

របាយការណ៍លទ្ធផលការងារ ឆ្លុះបញ្ចាំងអំពីលទ្ធផល និងវឌ្ឍនភាពនៃការអនុវត្តសកម្មភាពរបស់គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ដើម្បីឈានឆ្ពោះទៅសម្រេចផែនការមេក្នុងការព្រឹត្តិការណ៍ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ ២០២៣ ។ ព័ត៌មានអំពីលទ្ធផលការងារសម្រេចបាននេះ អាចជាបច្ច័យនាំទៅដល់ការសម្រេចចិត្តដើម្បីផ្លាស់ប្ដូរផែនការសកម្មភាព កែសម្រួលទំហំថវិកា ឬកែសម្រួលរបៀបគ្រប់គ្រងជាដើម ។ ក្នុងន័យនេះ ដើម្បីធានាបាននូវគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃការគ្រប់គ្រងថវិកា គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ និងគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ត្រូវតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើលទ្ធផលតាមពេលវេលាកំណត់ជាចាំបាច់ ។

### ៧.២. របាយការណ៍សន្និធិ

របាយការណ៍សន្និធិឆ្លុះបញ្ចាំងអំពីសមតុល្យសន្និធិ ដោយបង្ហាញនូវចលនាចេញ-ចូលនៃមុខសន្និធិនីមួយៗ ។ របាយការណ៍សន្និធិ ត្រូវឆ្លុះបញ្ចាំងអំពីសមតុល្យសន្និធិតាមប្រភេទនីមួយៗ និងតាមប្រភពធនធាន ព្រមទាំងត្រូវមានរបាយការណ៍សន្និធិខូចខាត ឬបាត់បង់ ដោយត្រូវបញ្ជាក់អំពីមូលហេតុ និងដំណោះស្រាយ ។ ទន្ទឹមនឹងនេះ របាយការណ៍សន្និធិ ត្រូវរំលេចអំពីបញ្ហាប្រឈម សំណូមពរ និងសំណើដំណោះស្រាយ ចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់សន្និធិ ។ របាយការណ៍សន្និធិ ត្រូវឆ្លុះបញ្ចាំងបន្ថែមអំពីសមតុល្យសន្និធិប្រើប្រាស់និងសន្និធិសំខាន់ៗមួយចំនួនដែលបានបញ្ជាទិញរួចហើយ និងកំពុងដឹកជញ្ជូន ព្រមទាំងផែនការសម្រាប់ទិញសន្និធិបន្ថែមទៀត ។

### ៧.៣. របាយការណ៍ទ្រព្យសម្បត្តិ

គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិ ត្រូវរៀបចំរបាយការណ៍ទ្រព្យសម្បត្តិ ដោយភ្ជាប់នូវបញ្ជីសារពើភណ្ឌដែលកត់ត្រាលម្អិតនូវទ្រព្យសម្បត្តិទាំងអស់ និង តារាងប្រៀបធៀបទ្រព្យសម្បត្តិកើនឡើង-ថយចុះ រួចផ្ញើមកគណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ។ របាយការណ៍ទ្រព្យសម្បត្តិ ត្រូវរំលេចអំពីបញ្ហាប្រឈម សំណូមពរ និងសំណើដំណោះស្រាយចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិ ។ គណៈកម្មការហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបដើម្បីផ្ញើជូនប្រធាន គ.ជ.ប.អ. តាមឋានានុក្រម និងតាមនីតិវិធី ។

## ផ្នែកទី ៨ ការត្រួតពិនិត្យ និងសវនកម្ម

ការគ្រប់គ្រងថវិកាមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣ ជាកម្មវត្ថុនៃការត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្មផ្ទៃក្រៅ ដោយឈរលើគោលការណ៍អនុលោមភាពនៃច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីហិរញ្ញវត្ថុ ។ គណៈកម្មការជំនាញ និងអង្គភាពប្រតិបត្តិនីមួយៗ ត្រូវទទួលខុសត្រូវចំពោះការធ្វើសវនកម្មនេះ ។

**ឧបសម្ពន្ធទី ១ គោលការណ៍សំខាន់ៗនៃនីតិវិធី SOP**

**១) សាវតាសង្ខេបនៃនីតិវិធីរួម÷** រាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ហៅកាត់ថា SOP តាមរយៈអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩។ នីតិវិធីរួមនេះ រួមមាន÷ ១) នីតិវិធីរួមសម្រាប់ការគ្រប់គ្រងគម្រោង (Standard Operating Procedures on Project Management), ២) នីតិវិធីរួមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង (Standard Operating Procedure on Financial Management) និង ៣) នីតិវិធីរួមសម្រាប់ការគ្រប់គ្រងកិច្ចលទ្ធកម្មគម្រោង (Standard Operating Procedure on Procurement) ក្រោមក្របខណ្ឌហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានានៅកម្ពុជា ។

**២) គោលបំណង÷** នីតិវិធីរួម មានគោលបំណងផ្តល់នូវគោលការណ៍ណែនាំ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោង/កម្មវិធីហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងយន្តការស្ថាប័ន (តួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងវដ្តរបស់គម្រោង) សម្រាប់គ្រប់ដំណាក់កាលនៃវដ្តគម្រោង រាប់ចាប់ពីដំណាក់កាលនៃការកំណត់អត្តសញ្ញាណកម្មគម្រោង រហូតដល់ការវាយតម្លៃក្រោយបញ្ចប់គម្រោង សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈដែលហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍នៅកម្ពុជា ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, និងចីរភាព ។

**៣) វិសាលភាព÷** ឯកសារនីតិវិធីរួមសម្រាប់ការគ្រប់គ្រងគម្រោង មានវិសាលភាពគ្របដណ្តប់តែគម្រោងហិរញ្ញ-ប្បទានដោយដៃគូអភិវឌ្ឍន៍ប៉ុណ្ណោះ ពោលគឺ មិនគ្របដណ្តប់លើគម្រោងវិនិយោគសាធារណៈ ដោយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ, គម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public Private Partnership), គម្រោងហិរញ្ញប្បទានដោយឥណទានពាណិជ្ជកម្ម, និងគម្រោងដោយការធ្វើឯកជនភាវូបនីយកម្មទ្រព្យសម្បត្តិរដ្ឋ ដែលអនុវត្តក្រោមក្របខណ្ឌគតិយុត្ត និងនីតិវិធីដាច់ដោយឡែករបស់រាជរដ្ឋាភិបាល។

**៤) តម្លៃបន្ថែមនៃការអនុវត្តនីតិវិធីរួម (SOP) ក្នុងសម្រាប់ គ.ជ.ប.អ. ក្នុងក្របខ័ណ្ឌថវិកាជាតិ÷** ការអនុវត្តនីតិវិធីរួម (SOP) ជាពិសេស នីតិវិធីរួមសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង (SOP/FMM) ក្នុងនោះ មានការអនុវត្តនីតិវិធីផ្តល់**បុរេប្រទាន/ជម្រះបញ្ជី/បំពេញឡើងវិញ** (Advance payment/liquidation/ replenishment) ដោយឈរលើមូលដ្ឋាននៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ (Annual Workplan and Budget/AWBP) នឹងជួយជំរុញដល់ការអនុវត្តគម្រោងបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។

**ឧបសម្ព័ន្ធទី ២ ឯកសារយោង**

- អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៨ ស្តីពីមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជាឆ្នាំ២០២៣
- អនុក្រឹត្យលេខ ២២៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣
- អនុក្រឹត្យលេខ ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការសម្រួលមាត្រា២ និងមាត្រា៧ នៃអនុក្រឹត្យលេខ ២២៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣
- អនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមសម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍
- សេចក្តីសម្រេចលេខ ១៨៩ សសរ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣
- សេចក្តីសម្រេចលេខ ១១២ សសរ. ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងសមាសភាពដឹកនាំនៃគណៈកម្មការនិងលេខាធិការដ្ឋាននៃ គ.ជ.ប.អ.
- សេចក្តីសម្រេចលេខ ៥១ សសរ. ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ ស្តីពីការតែងតាំងបន្ថែម និងផ្លាស់ប្តូរសមាសភាពរបស់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣
- ប្រកាសលេខ ៧២៦ សហវ.ប្រក ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៩ ស្តីពីវិធាន និងនីតិវិធីអនុវត្តចំណាយមូលនិធិកីឡាអាស៊ីអាគ្នេយ៍កម្ពុជា ឆ្នាំ២០២៣
- សេចក្តីសម្រេចលេខ ០៤៤ សហវ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការការបង្កើតក្រុមការងាររៀបចំថវិកាសម្រាប់ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣
- សេចក្តីសម្រេចលេខ ០០១/២០ ស.ស.រ. គ.ជ.ប.អ. ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០២០ ស្តីពីការការកំណត់របៀបរបបការងារនិងការបែងចែកភារកិច្ចជូនអគ្គលេខាធិការ អគ្គលេខាធិការរង នៃគណៈកម្មការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣
- សេចក្តីសម្រេចលេខ ០១២ គ.ជ.ប.អ. ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាព តួនាទី និងភារកិច្ចរបស់គណៈកម្មការនានា និងលេខាធិការដ្ឋាននៃគណៈកម្មការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ ឆ្នាំ២០២៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ៣៣៦.....[illegible].....[illegible].....[illegible]

ថ្ងៃ.[illegible]. ខែ.[illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...[illegible]... ខែ.[illegible]. ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១២៦២/១៣ គ.វ.ក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមហ៊ុន អាយខេ អ៊ីកែរីល

## សម្រេច

<u>**ប្រការ១៖**</u> អនុញ្ញាតឱ្យក្រុមហ៊ុន **អាយខេ អ៊ីកែរីល** (**IK APPAREL CO., LTD**) តំណាងដោយលោក **PEK POH KWEE** សញ្ជាតិសិង្ហបុរី កាន់លិខិតឆ្លងដែនលេខ **K1897981E** ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០ បង្កើតរោងចក្រ**កាត់ដេរសម្លៀកបំពាក់** ដែលមានទីតាំងស្ថិតនៅ**ផ្លូវជាតិលេខ៣ ភូមិអន្លង់រមៀតខាងលិច ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល**។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
| --- | --- |
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រកាត់ដេរសម្លៀកបំពាក់ អាយខេ អ៊ីកែរីល** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ០៥៣ ឧស.កឧ.ប្រក.០២ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**ម៉ាន សុភា**

<u>**ចម្លងជូន៖**</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-រាជកិច្ច
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកណ្តាល
-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តកណ្តាល
-រដ្ឋបាលស្រុកកណ្តាលស្ទឹង
-រដ្ឋបាលឃុំអន្លង់រមៀត
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២២

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ១៣៣២/១៣ គ.វ.ក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតអំបោះដេរ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ហ្គោលដេន យូណាយធីត ផលីអេស្ទែរ

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលដេន យូណាយធីត ផលីអេស្ទែរ (**GOLDEN UNITED POLYESTER CO., LTD.**) តំណាងដោយលោក **NORMAN PURNOMO NG** សញ្ជាតិឥណ្ឌូនេស៊ី កាន់លិខិតឆ្លងដែនលេខ**X896906** ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៩ បង្កើតរោងចក្រផលិតអំបោះដេរ ដែលមានទីតាំងស្ថិតនៅភូមិប្រទះឡាង សង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
| --- | --- |
| អំបោះដេរ | ១៣១១ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " រោងចក្រផលិតអំបោះដេរ ហ្គោលដេន យូណាយធីត ផលីអេស្ទែរ "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបាន ឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការ របស់រោងចក្រស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៣៣៩ ឧស.កឧ.ប្រក.១០ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងបរិស្ថាន
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -រាជកិច្ច
- -វិទ្យាស្ថានស្តង់ដារកម្ពុជា
- -មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- -សាលារាជធានីភ្នំពេញ
- -មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ
- -រដ្ឋបាលខណ្ឌកំបូល
- -រដ្ឋបាលសង្កាត់ប្រទះឡាង

"ដើម្បីជូនជ្រាប"
- -ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ០២២៦/១៤ ស.ត.ស.ព ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ ស្តីពីការវិនិយោគបង្កើតរោងចក្រផលិតបាល់ (Baseballs, Softballs) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំបន្តសុពលភាពវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ របស់ក្រុមហ៊ុន ស្ព្រុត ស្ព័ត

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន **ស្ព្រុត ស្ព័ត (SPROTT SPORTS CO., LTD.)** តំណាងដោយលោក **CHEN, SHYI-MING** សញ្ជាតិចិន(តៃវ៉ាន់) កាន់លិខិតឆ្លងដែនលេខ **353496866** ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩ បង្កើតរោងចក្រ**ផលិតបាល់ (Baseballs, Softballs)** ដែលមានទីតាំងស្ថិតនៅ**តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ)**។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
| --- | --- |
| បាល់ (Baseballs, Softballs) | ៣២៣០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ "**រោងចក្រផលិតបាល់** (Baseballs, Softballs) **ស្គ្រត ស្ព័ត** "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣-ថ្មី មាត្រា១៨-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រយៈពេល០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩-ថ្មី នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** ប្រកាសបង្កើតរោងចក្រលេខ៣៧២ ឧស.កឧ.ប្រក.១១ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះតាមមុខការ រៀងៗខ្លួន។

**ប្រការ១៦៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**
**រដ្ឋលេខាធិការ**

**មាន សុភា**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- រាជកិច្ច
- វិទ្យាស្ថានស្តង់ដារកម្ពុជា
- មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
- សាលាខេត្តព្រះសីហនុ
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខេត្តព្រះសីហនុ
- អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ
- រដ្ឋបាលស្រុកព្រៃនប់
- រដ្ឋបាលឃុំបិតត្រាំង និងឃុំរាម
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៩៤២១ រ៉ែ.អបក.ជក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
# លេខ០៩៧២១ រ៉ែ.អបក.លអ.....ចុះថ្ងៃទី......០៤......ខែ..កញ្ញា....ឆ្នាំ២០២១.

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយចម្រុះប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ របស់លោកស្រី **ម៉ុម សុទ្ធាវី**
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្ដល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោឈ្មោះ **ដេប៉ូតេលា លី គីមហេង** ស្ថិតនៅភូមិភារកិច្ច សង្កាត់ប៉ាលហាល ក្រុងព្រះវិហារ ខេត្តព្រះវិហារ របស់លោកស្រី **ម៉ុម សុទ្ធាវី (ម្ចាស់ស្ថានីយ)**។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងបរិវេណស្ថានីយ
២. កបំពង់ទទួលប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ម៉ែត្រ ពី អគារ
៣. ពោងប្រេងឥន្ធនៈមួយដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៤. មិនត្រូវបំពាក់វ៉ាន បិទ បើក នៅជាប់នឹងតួបំពង់ខ្យល់ប្រេងឥន្ធនៈ

៥. ត្រូវមានរបាំងការពារការប៉ះទង្គិចបំពង់ខ្យល់ប្រេងឥន្ធនៈ

៦. ត្រូវមានឃ្លុបការពារកបំពង់ទទួលប្រេងឥន្ធនៈ

៧. ត្រូវបំពាក់គន្លឹះអាសន្ននៅតាមទូចាក់ប្រេងឥន្ធនៈនីមួយៗ និងគន្លឹះអាសន្នរួម

៨. ទូចាក់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ម៉ែត្រ ពីអគារ

៩. ទុយោទូចាក់ប្រេងឥន្ធនៈមិនត្រូវមានប្រវែងលើសពី ៦ម៉ែត្រ

១០. ត្រូវមានគូសគំនូសសញ្ញាសម្រាប់ចំណតរថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ

១១. ត្រូវមានប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

១២. ត្រូវមានស្លាកសញ្ញាបម្រាមស្ដីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

១៣. ត្រូវមានផ្ទាំងព័ត៌មានស្ដីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្ដាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.–**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.–**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៩៧.១ រ៉ែ.អបក.លអ........ចុះថ្ងៃទី.....០៧.............ខែ...កញ្ញា.......ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.–**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៩៧.១ រ៉ែ.អបក.លអ. ចុះថ្ងៃទី......០៧.....ខែ......កញ្ញា......ឆ្នាំ២០២១...នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.–**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តព្រះវិហារ និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៧..ខែកញ្ញា....ឆ្នាំ២០២១.

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ_សែម**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រដ្ឋបាលខេត្តព្រះវិហារ
-ដូចប្រការ១៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ០៩៧៣ រ៉ែ.អប្រក.លអ

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ
# លេខ ០៩៧៣ រ៉ែ.អប្រក.លអ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ២០២១

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ១៣៧អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់
- បានឃើញប្រកាសរួមលេខ១២៨សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ដោយក្រសួងរ៉ែ និងថាមពល
- បានឃើញប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ ( ៥១ ) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ ( ៨៥៥ ) ២៣ ២១៩ ៥៧៤ ទូរសារ ( ៨៥៥ ) ២៣ ២១៩ ៥៨៤
#79-89, Pasteur Street(51), Sangkat Phsar Thmey3, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

- បានឃើញសារាចរលេខ០១៤០ រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់រៀបចំស្ថានីយប្រេងឥន្ធនៈ ឧស្ម័នឥន្ធនៈ និងស្ថានីយរួបប្រេងនិងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល
- បានឃើញសំណើចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ របស់លោក ឡេង ស្រ៊ួយហុាំង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែ និងថាមពល។

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់លក្ខខណ្ឌ ក្នុងការផ្តល់លិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈ មានស្លាកយីហោ **LHR** ត្រពាំងស្មាច់ ស្ថិតនៅភូមិត្រពាំងស្មាច់ ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង របស់លោក **ឡេង ស្រ៊ួយហុាំង** (ម្ចាស់ស្ថានីយ)។

**ប្រការ២.-**

ម្ចាស់ស្ថានីយត្រូវតាំងបង្ហាញលិខិតអនុញ្ញាតដំណើរការស្ថានីយនៅទីតាំងដែលងាយមើលឃើញក្នុងស្ថានីយរបស់ខ្លួន។

**ប្រការ៣.-**

ម្ចាស់ស្ថានីយត្រូវគោរព និងអនុវត្តតាមប្រកាសលេខ០១៤១រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈរបស់ក្រសួងរ៉ែ និងថាមពល ដោយត្រូវបំពេញបន្ថែមនូវឯកសារដូចខាងក្រោម ក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ៖

- លិខិតអនុញ្ញាតទីតាំងពីអាជ្ញាធរដែនដី
- លិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៤.-**

ម្ចាស់ស្ថានីយត្រូវគោរពនិងអនុវត្តតាមសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ របស់ក្រសួងរ៉ែនិងថាមពល ដោយត្រូវធ្វើការកែសម្រួលស្ថានីយរបស់ខ្លួនតាមសារាចរខាងលើឱ្យចប់ជាស្ថាពរក្នុងរយៈពេលមួយឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះនូវចំណុចបច្ចេកទេស ដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យមានលំនៅដ្ឋានក្នុងទីធ្លាស្ថានីយ
២. មិនអនុញ្ញាតឱ្យមានបញ្ចូល និងលក់ចែកចាយប្រេងឥន្ធនៈដាក់បីដុងជ័រក្នុងទីធ្លាស្ថានីយ
៣. ពោងប្រេងឥន្ធនៈមួយត្រូវដាក់ប្រេងឥន្ធនៈបានតែមួយប្រភេទប៉ុណ្ណោះ
៤. ពោងប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីលំនៅដ្ឋាន

៥. បំពង់ខ្យល់ប្រេងឥន្ធនៈត្រូវស្ថិតនៅចម្ងាយអប្បបរមា ៦ ម៉ែត្រពីលំនៅដ្ឋាន

៦. ត្រូវរៀបចំរបាំងការពារការប៉ះទង្គិចបំពង់ខ្យល់ប្រេងឥន្ធនៈ

៧. ត្រូវរៀបចំឃ្លុបការពារកបំពង់ទទួលប្រេងឥន្ធនៈ

៨. កបំពង់ទទួលប្រេងឥន្ធនៈ ត្រូវស្ថិតនៅចម្ងាយអប្បបរមា ៧ ម៉ែត្រពីអគាររបស់ស្ថានីយ

៩. ត្រូវបំពាក់គន្លឹះអាសន្នរួមមួយ និងគួរមានបំពាក់គន្លឹះអាសន្នតាមទូចាក់ប្រេងនីមួយៗ

១០. ទុយោចាក់ប្រេងឥន្ធនៈ មិនត្រូវមានប្រវែងលើសពី ៦ ម៉ែត្រ

១១. ត្រូវរៀបចំប្រព័ន្ធញែកសំណល់រឹង ប្រេង និងទឹក

១២. ត្រូវរៀបចំផ្ទាំងព័ត៌មានស្តីពីនីតិវិធីនៃការផ្ទេរប្រេងឥន្ធនៈ

១៣. ត្រូវបិទស្លាកសញ្ញាបម្រាមស្តីពីសុវត្ថិភាពឱ្យបានគ្រប់គ្រាន់

១៤. ត្រូវគូសគំនូសសញ្ញាចំណតសម្រាប់រថយន្តស៊ីទែនផ្ទេរប្រេងឥន្ធនៈ។

**ប្រការ៥.-**

ម្ចាស់ស្ថានីយត្រូវគោរពតាមសេចក្តីណែនាំរបស់ក្រសួងរ៉ែ និងថាមពលក្នុងការដាក់វិធានការ បទប្បញ្ញត្តិផ្សេងៗ និងត្រូវគោរពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

**ប្រការ៦.-**

ម្ចាស់ស្ថានីយត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរ៉ែ និងថាមពលមុនប្រគល់សិទ្ធិឱ្យអ្នកដទៃទៀតគ្រប់គ្រងស្ថានីយជំនួសខ្លួន ប៉ុន្តែត្រូវទទួលខុសត្រូវលើគ្រប់សកម្មភាពនៃកិច្ចប្រតិបត្តិការស្ថានីយនេះ។

**ប្រការ៧.-**

ម្ចាស់ស្ថានីយត្រូវផ្តល់ឱ្យបានត្រឹមត្រូវ នូវទិន្នន័យបរិមាណប្រេងឥន្ធនៈ ដែលបានលក់ជាប្រចាំត្រីមាសនៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំនៅសប្តាហ៍ទី១ នៃឆ្នាំបន្ទាប់ មកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែនិងថាមពល។

**ប្រការ៨.-**

ម្ចាស់ស្ថានីយត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែ និងថាមពលក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងស្ថានីយមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៩.-**

ម្ចាស់ស្ថានីយត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបានអំពីហានិភ័យផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការនៃស្ថានីយរបស់ខ្លួន។

**ប្រការ១០.-**

ម្ចាស់ស្ថានីយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលរយៈពេល ១ (មួយ) ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការស្ថានីយជាស្ថាពរ។

**ប្រការ១១.-**

ប្រកាសនេះមានរយៈពេលសុពលភាពស្របតាមរយៈពេលសុពលភាព នៃលិខិតដំណើរការស្ថានីយ លេខ.០៩៦៣ រ៉ែ.អប៊ែក.ឈអ.........ចុះថ្ងៃទី..០៣...............ខែ.កញ្ញា........ឆ្នាំ២០២១...............របស់ក្រសួងរ៉ែ និងថាមពល និងអាចពន្យារបន្តបានស្របតាមលិខិតអនុញ្ញាតនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១២.-**

ក្នុងករណីស្ថានីយនេះផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ (ដប់ពីរ)ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយខាងលើ នោះលិខិតអនុញ្ញាតដំណើរការស្ថានីយលេខ.០៩៦៣ រ៉ែ.អប៊ែក.ឈអ ចុះថ្ងៃទី.....០៣.....ខែ.កញ្ញា...........ឆ្នាំ២០២១....នឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌឡើយ។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត អគ្គាធិការ ប្រធានមន្ទីររ៉ែ និងថាមពលខេត្តស្វាយរៀង និងម្ចាស់ស្ថានីយត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ..១១រោច...ខែ.ស្រាពណ៍..ឆ្នាំឆ្លូវ..ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..០៣ខែ.កញ្ញា...ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តស្វាយរៀង
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី